# សទ្ទានុក្រមបច្ចេកស័ព្ទ និងនិយមន័យ

## ស្តីពី

# ការប្រែប្រួលអាកាសធាតុ និងការបន្សាំ

ខែ ឧសភា ឆ្នាំ២០១១

# សេចក្តីផ្តើម

ប្រទេសនានានៅក្នុងអាងទន្លេមេគង្គក្រោម (LMB) ស្ថិតក្នុងចំណោមប្រទេសដែលងាយរងគ្រោះបំផុតនៅចំពោះមុខការប្រែប្រួលអាកាសធាតុលើពិភពលោក។ សេដ្ឋកិច្ច និរន្តរភាពនៃប្រព័ន្ធអេកូឡូស៊ី និងភាពសុខសាន្តខាងសង្គមកំពុងប្រឈមនឹងហានិភ័យ។

អាស្រ័យហេតុនេះ ប្រទេសទាំងនេះត្រូវការឲ្យមានការយល់ដឹងបានប្រសើរជាងមុនអំពីផលប៉ះពាល់ដែលអាចកើតចេញពីការប្រែប្រួលអាកាសធាតុ និងជាពិសេស ជម្រើសសម្រាប់ការបន្សុំាចំពោះការប្រែប្រួលទាំងនេះ។ គណៈកម្មការទន្លេមេគង្គ (MRC) គឺជាអង្គការសមស្របបំផុតមួយ សម្រាប់ដឹកនាំកិច្ចផ្តួចផ្តើមគ្រប់គ្រងការប្រែប្រួលអាកាសធាតុ និងការបន្សុំា (CCAI) ដែលបានទទួលការគាំទ្រតាមរយៈភាពជាដៃគូពហុម្ចាស់ជំនួយ។ បណ្តាប្រទេសនៅ LMB មានការប្តេជ្ញា នៅក្នុងកិច្ចផ្តួចផ្តើមសហការថ្នាក់តំបន់មួយនេះ ដែលអាចគាំទ្រដល់ប្រទេសទាំងនេះនៅក្នុងការបន្សុំាទៅនឹងការប្រឈមថ្មីៗ ដែលបង្កដោយការប្រែប្រួលអាកាសធាតុ ដោយបង្កើតឲ្យមានដំណើរការជាប្រព័ន្ធមួយសម្រាប់កសាងផែនការ ការអនុវត្ត និងការសិក្សារៀនសូត្រ។

សទ្ទានុក្រមនេះ ត្រូវបានរៀបរៀងឡើងក្នុងគោលបំណងចាប់ផ្តើមធ្វើការឆ្ពោះទៅរកការយល់ដឹងរួមមួយអំពីវាក្យស័ព្ទ និងគោលគំនិតសំខាន់ៗមួយចំនួន អំពីការប្រែប្រួលអាកាសធាតុ និងការបន្សុំា ដែលពាក់ព័ន្ធនៅក្នុងតំបន់មេគង្គ និងដែលសម្រួលដល់ការកសាងសមត្ថភាពជាតិ ចំណេះដឹង ការយល់ដឹង និងព័ត៌មានអំពីការប្រែប្រួលអាកាសធាតុ។ សទ្ទានុក្រមនេះគឺជា ឧបករណ៍រស់រវើកមួយ ដែលនឹងត្រូវធ្វើបច្ចុប្បន្នភាព ដោយបញ្ចូលវាក្យស័ព្ទថ្មីៗតាមការចាំបាច់។

នៅក្នុងការរៀបរៀងសទ្ទានុក្រមនេះ កិច្ចផ្តួចផ្តើម CCAI នៃ MRC បានកំណត់អត្តសញ្ញាណ និងពិនិត្យមើលវាក្យស័ព្ទ និងទស្សនាទាននានាដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ និងការបន្សុំា នៅក្នុងបរិបទនៃអាងទន្លេមេគង្គ ដោយយោងលើសទ្ទានុក្រម និង វាក្យស័ព្ទនានា ដែលបានមកពីប្រភពទទួលស្គាល់ជាផ្លូវការ និងតាមបែបវិទ្យាសាស្ត្រ ដូចជា អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) ក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ (IPCC) យុទ្ធសាស្ត្រអន្តរជាតិសម្រាប់ការកាត់បន្ថយគ្រោះមហន្តរាយរបស់អង្គការសហប្រជាជាតិ (UNISDR) ជាដើម។ ខាងក្រោយនិយមន័យ ឬទស្សនាទានរបស់វាក្យស័ព្ទនិមួយៗ មានសេចក្តីពន្យល់ ឧទាហរណ៍ និង ការបញ្ជាក់បន្ថែមនានា តាមការចាំបាច់។

## អក្សរកាត់ និង ពាក្យបំព្រួញ

| | | |
|---|---|---|
| AOGCMs | Atmosphere-Ocean General Circulation Models | ម៉ូដែលចរន្តទូទៅបរិយាកាសនិងមហាសមុទ្រ |
| CDM | Clean Development Mechanism | យន្តការអភិវឌ្ឍន៍ស្អាត |
| CCAI | Climate Change and Adaptation Initiative (of the MRC) | កិច្ចផ្តួចផ្តើមប្រែប្រួលអាកាសធាតុនិងការបន្សាំ (នៃគណៈកម្មការទន្លេមេគង្គ) |
| COP | Conference of the Parties | សន្និសីទភាគី |
| DGVM | Dynamic Global Vegetation Model | ម៉ូដែលឌីណាមិកគម្របរុក្ខជាតិលើពិភពលោក |
| ENSO | El Niño-Southern Oscillation | ចរន្តទឹកក្តៅអែលនីញ៉ូខាងត្បូង |
| GCM | General Circulation Model | ម៉ូដែលចរន្តទូទៅ |
| GDP | Gross Domestic Product | ផលិតផល/ផលទុនក្នុងស្រុកសរុប |
| GHG | Greenhouse gas | ឧស្ម័នផ្ទះកញ្ចក់ |
| GWP | Global Warming Potential | សក្តានុពលកំដៅពិភពលោក |
| IPCC | Intergovernmental Panel on Climate Change | ក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ |
| LDCs | Least Developed Countries | ប្រទេសដែលមានការអភិវឌ្ឍតិចតួច |
| LMB | Lower Mekong Basin | អាងទន្លេមេគង្គក្រោម |
| MRC | Mekong River Commission | គណៈកម្មការទន្លេមេគង្គ |
| NAPAs | National Adaptation Programmes of Action | កម្មវិធីសកម្មភាពជាតិសម្រាប់ការបន្សាំ |
| NTP | National Target Programme (of Viet Nam) | កម្មវិធីចំណុចដៅជាតិ(នៃប្រទេសវៀតណាម) |
| OECD | Organisation for Economic Cooperation and Development | អង្គការដើម្បីសហប្រតិបត្តិការនិងអភិវឌ្ឍន៍សេដ្ឋកិច្ច |
| SIDS | Small Island Developing States | រដ្ឋកំពុងអភិវឌ្ឍន៍នៅលើកូនកោះ |
| SRES | Special Report on Emissions Scenarios | របាយការណ៍ពិសេសស្តីពីសេណារីយ៉ូបំភាយ |
| UN | United Nations | អង្គការសហប្រជាជាតិ |
| UNCCD | United Nations Convention to Combat Desertification | អនុសញ្ញាសហប្រជាជាតិប្រឆាំងរហោស្ថានកម្ម |
| UNFCCC | United Nations Framework Convention on Climate Change | អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ |
| UNEP | United Nations Environment Programme | កម្មវិធីបរិស្ថានសហប្រជាជាតិ |
| WMO | World Meteorological Organisation | អង្គការឧតុនិយមពិភពលោក |

## A.

### Acclimatisation ភាពសុាំទៅនឹងអាកាសធាតុថ្មី

*ការបន្សុាំ* ខាងសរីរៈសាស្ត្រទៅនឹងការប្រែប្រួលនានានៃអាកាសធាតុ។

### Adaptability ភាពបន្សុាំបាន

សូមអាន *សមត្ថភាពបន្សុាំ។*

### Adaptation ការបន្សុាំ

កំណែតម្រូវនៃ *ប្រព័ន្ធមនុស្ស* ឬ ធម្មជាតិ ដែលជាការឆ្លើយតបទៅនឹងកត្តាជម្រុញនៃអាកាសធាតុ ឬ ផលវិបាករបស់វា ដែលបន្ធូរបន្ថយការខូចខាត ឬ ទាញយកផលពីឱកាសវិជ្ជមាននានា។

*IPCC* បែងចែកការបន្សុាំទៅជាជំពូកខុសៗគ្នាដូចតទៅៈ

- **ការបន្សុាំដោយគ្រោងទុក** - ការបន្សុាំដែលកើតឡើងមុនពេលដែលសង្កេតឃើញថាមានផលប៉ះពាល់នៃ *ការប្រែប្រួលអាកាសធាតុ*។ ត្រូវបានហៅផងដែរថាជា ការបន្សុាំដោយគិតទុកជាមុន។
- **ការបន្សុាំដោយឯកឯង** - ការបន្សុាំដែលមិនបានដឹងជាមុនថាវាជាការឆ្លើយតបទៅនឹង *កត្តាជម្រុញ* នៃអាកាសធាតុឡើយ ប៉ុន្តែបានធ្វើឡើយដោយសារតែការប្រែប្រួលនៃអេកូឡូស៊ីនៅក្នុងប្រព័ន្ធធម្មជាតិ និងដោយសារទីផ្សារ ឬការប្រែប្រួលនៃ *សុខុមាលភាព* នៅក្នុងប្រព័ន្ធមនុស្ស។ ត្រូវឲ្យឈ្មោះផងដែរថា ការបន្សុាំសយម្ភូត។
- **ការបន្សុាំដោយគ្រោងទុក** - ការបន្សុាំដែលជាលទ្ធផលនៃចេតនាខាងនយោបាយ ដោយផ្អែកលើការយល់ដឹងថា លក្ខខណ្ឌនានាបានប្រែប្រួល ឬ ហៀបនឹងប្រែប្រួល ហើយចំណាត់ការនោះ គឺជាការចាំបាច់ដើម្បីបង្វែរទិស រក្សាស្ថិរភាព ឬ សម្រេចឲ្យបាន នូវស្ថានភាពណាមួយតាមការចង់បាន។
- **ការបន្សុាំជាឯកជន** - ការបន្សុាំដែលបានផ្តួចផ្តើមឡើង និងអនុវត្ត ដោយបុគ្គល គ្រួសារ ឬក្រុមហ៊ុនឯកជន។ តាមធម្មតា ការបន្សុាំជាឯកជនធ្វើឡើងសម្រាប់ហេតុផលដែលបម្រើប្រយោជន៍ខ្លួនឯង។
- **ការបន្សុាំជាសាធារណៈ** - ការបន្សុាំដែលផ្តួចផ្តើមឡើង និងអនុវត្តដោយរដ្ឋាភិបាលនៅគ្រប់លំដាប់ថ្នាក់។ តាមធម្មតា ការបន្សុាំជាសាធារណៈ គឺជាការឆ្លើយតបទៅនឹងតម្រូវការចាំបាច់ជាសមូហភាព។
- **ការបន្សុាំបែបប្រតិកម្ម** - ការបន្សុាំធ្វើឡើងក្រោយសង្កេតឃើញផលប៉ះពាល់នៃ *ការប្រែប្រួលអាកាសធាតុ*។

### Adaptation benefits - ផលប្រយោជន៍នៃការបន្សុាំ

ទំហំនៃការបង់ខាតដែលអាចបញ្ចៀសបាន ឬ ផលចំណេញដែលកើតឡើង បន្ទាប់ពីមានការបន្សុាំ និងការអនុវត្តវិធានការ *បន្សុាំ*។

### Adaptation costs - ថ្លៃចំណាយលើការបន្សុាំ

ថ្លៃចំណាយលើការកសាងផែនការ ការត្រៀមរៀបចំខ្លួន ការសម្របសម្រួល និងការអនុវត្តវិធានការបន្សុាំ ដែលរួមទាំង ថ្លៃចំណាយអន្តរកាលផងដែរ។

**Adaptive capactiy - សមត្ថភាពបន្សាំ (ទាក់ទងទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ)**

សមត្ថភាពនៃប្រព័ន្ធក្នុងការសម្របទៅនឹង*ការប្រែប្រួលអាកាសធាតុ* (ដែលរួមទាំង*វិសមរូបអាកាសធាតុ* និង ភាពកំណាច) ដើម្បីបន្ធូរបន្ថយការខូចខាតដែលអាចកើតឡើង ឬដើម្បីទាញយកប្រយោជន៍ពីឱកាសដែលមាន ឬ ដើម្បីទប់ទល់នឹងផលវិបាកនានាដែលកើតឡើង។

**Aggregate impacts - ផលប៉ះពាល់សរុប**

*ផលប៉ះពាល់* សរុប ដែលរួមបញ្ចូលគ្នានៅក្នុងវិស័យ និង/ឬ តំបន់នានា។ ការបូកបញ្ចូលផលប៉ះពាល់ ទាមទារឲ្យមានចំណេះដឹង(ឬសេចក្តីសន្មតិ)អំពីសារៈសំខាន់ធៀបនៃផលប៉ះពាល់នៅក្នុងវិស័យ ឬតំបន់ខុសៗគ្នា។ រង្វាស់នៃផលប៉ះពាល់សរុប អាចមានដូចជា ចំនួនប្រជាពលរដ្ឋដែលរងគ្រោះ ឬ ការខូចខាតសរុបជាផលចំណូលខាងសេដ្ឋកិច្ច។

**Anthropogenic - ដោយសារមនុស្ស/ពីសកម្មភាពមនុស្ស**

ដែលកើតចេញពី ឬ ជាផលិតផលរបស់មនុស្ស។

**Anthropogenic emissions - ការបំភាយពីសកម្មភាពមនុស្ស**

ការបំភាយឧស្ម័នផ្ទះកញ្ចក់ ជាតុផ្សំនៃឧស្ម័នផ្ទះកញ្ចក់ និងអាអេរ៉ូសូល ដែលពាក់ព័ន្ធជាមួយសកម្មភាពមនុស្ស។ ការបំភាយទាំងនេះកើតចេញពីការដុតឥន្ទនៈផូស៊ីល *ការបាត់បង់ព្រៃឈើ* ការប្រែប្រួលនៃការប្រើប្រាស់ដី ការចិញ្ចឹមសត្វ ការដាក់ជី ។ល។ ដែលនាំឲ្យមានកំណើននៃការបំភាយឧស្ម័ន ច្រើនជាងសម្រូបឧស្ម័ន។

## B.

**Baseline/reference – (លក្ខខណ្ឌ)គោល/យោង**

(លក្ខខណ្ឌ)គោល/យោង គឺជាស្ថានភាពដើម សម្រាប់ធៀបក្នុងការវាស់វែងភាពផ្លាស់ប្តូរ។ វាអាចជា'តួលេខគោលបច្ចុប្បន្ន' ដែលក្នុងករណីនេះវាតំណាងឲ្យលក្ខខណ្ឌដែលអាចសង្កេតឃើញនាពេលបច្ចុប្បន្ន។ វាក៏អាចជា'តួលេខគោលអនាគត'ផងដែរ ដែលជាស្ថានភាពនៃអនាគតទៅតាមការនិទស្សន៍ ដោយមិនគិតបញ្ចូលកត្តាជម្រុញដែលត្រូវវាស់។ ការបកស្រាយអំពីលក្ខខណ្ឌយោងតាមវិធីផ្សេងជាជំនួស អាចផ្តល់នូវលក្ខខណ្ឌគោលជាច្រើន។

**Base year - ឆ្នាំគោល**

មានន័យថា ជាការកំណត់ឆ្នាំគោលមួយដើម្បីឲ្យការបំភាយឧស្ម័ន ត្រូវបានវាស់វែងផ្ទៀងផ្ទាត់ត្រឹមត្រូវ នៅក្នុងអំឡុងរយៈពេលណាមួយ។

ឆ្នាំ ១៩៩០ គឺជាឆ្នាំគោលដែលប្រើប្រាស់នៅក្នុង *UNFCCC* និងក៏សម្រាប់ការកំហិតលើការបំភាយឧស្ម័នភាគច្រើនដែលត្រូវគណនា និងជាឆ្នាំគោលនៃការប្តេជ្ញាកាត់បន្ថយ ដូចដែលបានកំណត់នៅក្រោម*ពិធីសារក្យូតូ* ផងដែរ។

ទោះជាយ៉ាងណាក៏ដោយ ប្រទេសនានាដែលស្ថិតក្នុងសេដ្ឋកិច្ចអន្តរកាល ដែលជ្រើសយកឆ្នាំគោលខុសគ្នា ដូចដែលបានសម្រេចនៅក្នុងកិច្ចប្រជុំនៃសន្និសីទភាគីលើកទីពីរ (COP2) ត្រូវប្រើប្រាស់ឆ្នាំគោលនោះនៅក្រោមពិធីសារក្យូតូ។ ទន្ទឹមនឹងនេះ ភាគីទាំងអស់ក្នុងឧបសម្ព័ន្ធ ១ មានសិទ្ធិជ្រើសយកឆ្នាំ ១៩៩៥ ជាឆ្នាំគោលសម្រាប់ការបំភាយរបស់ពួកគេនូវឧស្ម័នបីបែបពីឧស្សាហកម្ម ដូចមានចែងក្នុងពិធីសារនេះ ពោលគឺ អ៊ីដ្រូហ្វ្លុយអ័រ៉ូកាបូន ពែរហ្លុយអ័រ៉ូកាបូន និងស៊ុលហ្វួរអិចសាហ្លុយអ័រីត។ លក្ខខណ្ឌនេះក៏ត្រូវប្រើប្រាស់ សម្រាប់ការធ្វើរបាយការណ៍ដោយស្ម័គ្រចិត្តផងដែរ និងជាទូទៅសំដៅលើឆ្នាំដំបូងដែលមានការរៀបចំសារពើភ័ណ្ឌ *ឧស្ម័នផ្ទះកញ្ចក់* (*GHG*)។

## C.

### Capacity Building - **ការកសាងសមត្ថភាព**

នៅក្នុងបរិបទនៃ *ការប្រែប្រួលអាកាសធាតុ* ការកសាងសមត្ថភាព គឺការអភិវឌ្ឍជំនាញបច្ចេកទេស និងសមត្ថភាពស្ថាប័ននៃប្រទេស និងសេដ្ឋកិច្ចនានា ដើម្បីអាចឲ្យពួកគេចូលរួមនៅក្នុងគ្រប់ទិដ្ឋភាពនៃ *ការបន្សាំ ការកាត់បន្ថយ* និងការស្រាវជ្រាវអំពី *ការប្រែប្រួលអាកាសធាតុ* និង នៅក្នុងការអនុវត្តយន្តការក្យូតូ។ល។

### Carbon cycle - **វដ្តកាបូន**

ពាក្យនេះត្រូវបានប្រើប្រាស់សម្រាប់អធិប្បាយអំពីលំហូរកាបូន (តាមទម្រង់ខុសៗគ្នា ដូចជា *ឧស្ម័នកាបូនិក*) តាមរយៈ *បរិយាកាស* មហាសមុទ្រ *ជីវៈមណ្ឌល*ជែនដីគោក និងមណ្ឌលថ្ម។

### Carbon dioxide - **ឧស្ម័នកាបូនិក** ($CO_2$)

ឧស្ម័នដែលកើតឡើងតាមធម្មជាតិ ដែលស្រូប *តាមរយៈដំណើរស្មើសំយោគ* ដើម្បីបម្លែងជាសារធាតុសរីរាង្គ។ វាជាអនុផលនៃចំហេះឥន្ធនៈផូស៊ីលនិងដំណុត *ជីវៈម៉ាស*។ វាក៏បំភាយចេញពី *ដំណាកដង្ហើម*តាមធម្មជាតិ និងដំណើរការរលួយ និងចេញពីដំណើរការឧស្សាហកម្មខុសៗគ្នាផងដែរ។ វាជា *ឧស្ម័នផ្ទះកញ្ចក់ចំបងមួយដែលបានពីសកម្មភាពមនុស្ស* និងដែលមានឥទ្ធិពលមកលើតុល្យភាពនៃកាំរស្មីដែលចាំងមកលើផ្ទៃផែនដី។ វាជាឧស្ម័នយោង សម្រាប់ជាខ្នាតដើម្បីវាស់ ឧស្ម័នផ្ទះកញ្ចក់ដទៃទៀត ដូច្នេះវាមាន *សក្តានុពលកំដៅផែនដី* ស្មើ ១។

### Carbon Footprint - **ស្លាកស្នាមកាបូន**

ការបំភាយ *ឧស្ម័នផ្ទះកញ្ចក់*ទាំងអស់ ដែលពាក់ព័ន្ធជាមួយសកម្មភាពរបស់បុគ្គល ឬ អង្គភាពណាមួយ។

### Carbon Sequestration - **សម្រួបកាបូន**

ការបញ្ចេញ ឬ ស្តុកទុកកាបូនពី *បរិយាកាស* នៅក្នុងអន្លង់កាបូន (ដូចជា មហាសមុទ្រ ព្រៃឈើ ឬ ដី) តាមរយៈដំណើរការរូបសាស្ត្រ ឬ ជីវសាស្ត្រ ដូចជា រស្មីសំយោគ។ ជាគោលការណ៍ សម្រួបកាបូន សំដៅលើកាបូនដែលនឹងត្រូវបំភាយចេញទៅក្នុង *បរិយាកាស* ប្រសិនបើគ្មានសន្និធិនេះទេ។ មានវិធីចំបងៗចំនួនបី នៅក្នុងស្ថានភាពខុសៗគ្នានៃបេកគំហើញ និងការអភិវឌ្ឍ៖ ១) សន្និធិរយៈពេលខ្លី នៅក្នុង *ជីវៈមណ្ឌល*ជែនដីគោក ដែលរុក្ខជាតិស្រូបយក $CO_2$ និងរក្សាទុកកាបូននៅក្នុង *ជីវៈម៉ាស* និងក្នុងដី ២) សន្និធិរយៈពេលវែងនៅក្នុងស្រទាប់ដីនៃផែនដី ដោយការបូមបញ្ចូល $CO_2$ ទៅក្នុង *អាង*ដែលមានស្រាប់ ឬ ដែលកើតពីការខួង/ជីកចុះទៅក្នុងស្រទាប់នៃផែនដី ៣) សន្និធិរយៈពេលវែង នៅក្នុងមហាសមុទ្រនៃផែនដី ដែល $CO_2$ អាចត្រូវគេបាញ់បញ្ចូលទៅក្នុងជម្រៅដីជាច្រើនពាន់ហ្វីត និងស្រូបចូលទៅក្នុងទឹក។

**Carbon stock - ស្តុកកាបូន**

បរិមាណកាបូននៅក្នុង*អាង*/អន្លង់ ដែលមានសមត្ថភាពក្នុងការប្រមូលផ្តុំ ឬ បំភាយកាបូន។

**CDM (Clean Development Mechanism)- យន្តការអភិវឌ្ឍន៍ស្អាត**

CDM អនុញ្ញាតឲ្យមានគម្រោងកាត់បន្ថយការបំភាយ *ឧស្ម័នផ្ទះកញ្ចក់* ដែលអនុវត្តនៅក្នុងប្រទេសនានា ដែលពុំមានចំណុចដៅនៃការបំភាយនៅក្រោម*ពិធីសារក្យូតូ*នៃ*អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC)* ប៉ុន្តែគឺជាភាគីហត្ថលេខី។ ការកាត់បន្ថយនូវការបំភាយដែលពាក់ព័ន្ធនេះត្រូវបានផ្តល់ទៅឲ្យប្រទេសដែលជាអ្នកផ្តល់មូលនិធិសម្រាប់គម្រោងនោះ ដែលជាប្រទេសមានកំណត់ចំណុចដៅនៃការបំភាយ។

**Climate - អាកាសធាតុ**

អាកាសធាតុនៅក្នុងន័យជាក់លាក់ តាមធម្មតាត្រូវបានឲ្យនិយមន័យថាជា "*ធាតុអាកាស*មធ្យម" ឬ ជាក់លាក់ជាងនេះទៀត គឺជាសេចក្តីពិព៌ណនាតាមរូបមន្តស្ថិតិថាជា តួលេខមធ្យម និងវិសមរូបនៃបរិមាណដែលពាក់ព័ន្ធ នៅក្នុងអំឡុងពេលណាមួយ ដែលរាប់ចាប់ពីជាច្រើនខែ រហូតដល់ជាច្រើនពាន់ ឬ លានឆ្នាំ។ ជាញឹកញាប់ បរិមាណទាំងនេះគឺជាអថេរ នៅក្នុងស្រទាប់លើនៃផែនដី ដូចជា សីតុណ្ហភាព កំពស់ទឹកភ្លៀង និងខ្យល់។ ក្នុងន័យទូលាយ អាកាសធាតុគឺជាស្ថានភាពដែលរួមទាំង សេចក្តីពិព៌ណនាតាមរូបមន្តស្ថិតិអំពី*ប្រព័ន្ធអាកាសធាតុ*។ ជាទូទៅ បើផ្អែកតាមអង្គការឧតុនិយមពិភពលោក (WMO)អំឡុងពេលដែលពាក់ព័ន្ធគឺ ៣០ឆ្នាំ។

**Climate Change - ការប្រែប្រួលអាកាសធាតុ**

ការប្រែប្រួលនៃ*អាកាសធាតុ* ដែលជាប់ទាក់ទងដោយផ្ទាល់ ឬប្រយោលទៅនឹងសកម្មភាពមនុស្ស ដែលកែប្រែសមាសភាពនៃ*បរិយាកាស*ពិភពលោក និងដែលជាការបន្ថែមពីលើ*វិសមរូបអាកាសធាតុ*តាមធម្មជាតិ ដែលបានសង្កេតឃើញនៅក្នុងអំឡុងពេលវែងជាបង្គួរ។ សូមអាន*វិសមរូបអាកាសធាតុ*។

**Climate feedback - ប្រតិកម្មតបនៃអាកាសធាតុ**

ឥទ្ធិពលនៃដំណើរការដែលទាក់ទងនឹងអាកាសធាតុមកលើដំណើរការមួយផ្សេងទៀត ដែលបន្ទាប់មកក៏មានឥទ្ធិពលមកលើដំណើរការពីដំបូង។

ឧទាហរណ៍៖ ប្រតិកម្មតបជាវិជ្ជមានមួយនៃអាកាសធាតុ គឺកំណើនសីតុណ្ហភាព ដែលនាំឲ្យវិសាលភាពនៃតំបន់ទឹកកករួមតូច និងដែលនាំឲ្យមានការថយចុះនៃចំណាំងផ្លាតនៃកាំរស្មីពីព្រះអាទិត្យ (ដែលធ្វើឲ្យមានកំណើនសីតុណ្ហភាព)។ ឧទាហរណ៍មួយអំពីប្រតិកម្មតបអវិជ្ជមាននៃអាកាសធាតុគឺ កំណើនសីតុណ្ហភាពលើផ្ទៃផែនដី ដែលអាចនាំឲ្យមានកំណើនបរិមាណពពកនៅតាមកន្លែងនានា ដែលអាចកាត់បន្ថយសីតុណ្ហភាពលើផ្ទៃផែនដី។

**Climate model - ម៉ូដែលអាកាសធាតុ**

ការបង្ហាញដែលតំណាងដោយលេខគណិតអំពី*ប្រព័ន្ធអាកាសធាតុ* ដោយផ្អែកលើសំណុំលក្ខណៈរូប គីមី និងជីវសាស្ត្រ នៃសមាសភាគនានារបស់វា ពោលគឺអន្តរអំពើរវាងសមាសភាគទាំងនោះ និងដំណើរការ*ប្រតិកម្មតប* និងដែលគិតបញ្ចូលសំណុំលក្ខណៈទាំងអស់ ឬ ខ្លះៗដែលបានស្គាល់។

*ប្រព័ន្ធអាកាសធាតុ* អាចតំណាងដោយម៉ូដែល ដែលមានភាពស្មុគស្មាញ ក្នុងកម្រិតខុសៗគ្នា (ពោលគឺ ចំពោះសមាសភាគណាមួយ ឬបង្គុំនៃសមាសភាគមួយចំនួន គេអាចកំណត់នូវលំដាប់ថ្នាក់នៃម៉ូដែល តាមទម្រង់ខុសគ្នានៃចំនួនវិមាត្ររូប

វន្ត ពោលគឺ វិសាលភាពនៃដំណើរការរូបសាស្ត្រ គីមី និងជីវសាស្ត្រត្រូវបានបង្ហាញឲ្យឃើញជាក់លាក់ ឬ ក្នុងកម្រិតដែលមានការពាក់ព័ន្ធទៅនឹងការតាងដោយប៉ារ៉ាម៉ែត្រនៅក្នុងការពិសោធន៍។ ម៉ូដែលទ្វេចរន្តទូទៅបរិយាកាស-មហាសមុទ្រ (*AOGCMs*) បង្ហាញពីរូបភាពតំណាងដោយ*ប្រព័ន្ធអាកាសធា*តុពេញលេញមួយ។ ម៉ូដែលកាន់តែស្មុគស្មាញ ពាក់ព័ន្ធផងដែរជាមួយភាពសកម្មនៃកត្តាគីមី និងជីវសាស្ត្រ។ ម៉ូដែល*អាកាសធាតុ* ត្រូវបានប្រើប្រាស់ជាឧបករណ៍ស្រាវជ្រាវ ដើម្បីសិក្សា និងកែប្រែលក្ខខណ្ឌ*អាកាសធាតុ* ប៉ុន្តែក៏សម្រាប់គោលបំណងប្រតិបត្តិការផងដែរ ដែលរួមទាំង *ការទស្សន៍ទាយអាកាសធាតុ*ប្រចាំខែ ប្រចាំរដូវ និងរវាងឆ្នាំនានា។

Climate prediction - **ការទស្សន៍ទាយអាកាសធាតុ**

ការទស្សន៍ទាយ ឬ ព្យាករ អាកាសធាតុ គឺជាលទ្ធផលនៃការប៉ុនប៉ងមួយ ដើម្បីបង្កើតតួលេខប៉ាន់ស្មានអំពីការវិវត្តនៃ*អាកាសធាតុ*ទៅអនាគត ដូចជា នៅក្នុងអំឡុងពេលប្រចាំរដូវ ចន្លោះឆ្នាំ ឬ រយៈពេលវែងជាងនេះ។ សូមអាន*និទស្សន៍អាកាសធាតុ* និង *សេណារីយ៉ូ(ការប្រែប្រួល)អាកាសធាតុ*។

Climate projection - **និទស្សន៍អាកាសធាតុ**

ការគណនាអំពីប្រតិកម្មរបស់*ប្រព័ន្ធអាកាសធាតុ* តបទៅនឹង*ការបំភាយឧស្ម័ន* ឬ *សេណារីយ៉ូ* នៃកំហាប់*ឧស្ម័នផ្ទះកញ្ចក់* និង*អាអេរ៉ូសូល* ឬ *សេណារីយ៉ូកម្លាំងកាំរស្មី* ដែលច្រើនតែផ្អែកលើលំហាត់ត្រាប់តាមរយៈ*ម៉ូដែលអាកាសធាតុ*។ និទស្សន៍អាកាសធាតុមានភាពខុសគ្នាពី*ព្យាករណ៍អាកាសធាតុ* ត្រង់ថា*និទស្សន៍អាកាសធាតុ* ពឹងផ្អែកជាសំខាន់លើការបំភាយ/កំហាប់/*សេណារីយ៉ូនៃកាំរស្មីបង្កហេតុ* ដែលយកមកប្រើប្រាស់សម្រាប់គណនា ដូច្នេះផ្អែកលើការសន្មតដែលមានភាពមិនប្រាកដប្រជាកម្រិតខ្ពស់នៃការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម និងបច្ចេកវិទ្យាទៅអនាគត។

Climate scenario - **សេណារីយ៉ូអាកាសធាតុ**

ការបង្ហាញជាតំណាងដែលអាចប្រើការបាន និងជាញឹកញាប់គឺជាតំណាងងាយៗអំពី*អាកាសធាតុ*ទៅអនាគត ដោយផ្អែកលើទំនាក់ទំនងផ្ទៃក្នុងប្រកបដោយសង្គតិភាពនៃអថេរឧតុនិយម និងការសន្មតិអំពី*កម្លាំងកាំរស្មី* ដែលបានបង្កើតឡើងសម្រាប់តែការប្រើប្រាស់ជាធាតុចូលនៅក្នុងម៉ូដែល*ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ*។

Climate system - **ប្រព័ន្ធអាកាសធាតុ**

*ប្រព័ន្ធអាកាសធាតុ* ត្រូវបានឲ្យនិយមន័យថាជា ឌីណាមិក និងអន្តរអំពើនៃសមាសភាគចំបងៗចំនួនប្រាំ៖ *បរិយាកាស* មណ្ឌលទឹក *មណ្ឌលកក (គ្រីយ៉ូស្វ៊ែរ)* ផ្ទៃដី និង*ជីវមណ្ឌល*។ ឌីណាមិកនៃ*ប្រព័ន្ធអាកាសធាតុ* ស្ថិតក្រោមឥទ្ធិពលនៃកត្តាបង្កហេតុពីខាងក្នុងនិងក្រៅ ដូចជា បន្ទុះភ្នំភ្លើង វិសមរូបនៃពន្លឺព្រះអាទិត្យ ឬ ការកែប្រែដោយសារមនុស្ស មកលើតុល្យភាពនៃកាំរស្មីដែលចាំងមកលើផែនដី ដូចជា តាមរយៈ *ការបំភាយឧស្ម័នផ្ទះកញ្ចក់ដោយសារសកម្មភាពរបស់មនុស្ស* និង/ឬ ការប្រែប្រួលនៃការប្រើប្រាស់ដី។

Climate threshold - **ចំណុចចាប់ផ្តើមនៃអាកាសធាតុ**

ចំណុចដែល*កម្លាំងពីខាងក្រៅ* នៃ*ប្រព័ន្ធអាកាសធាតុ* ដូចជា កំណើនកំហាប់*ឧស្ម័នផ្ទះកញ្ចក់* នៅក្នុងបរិយាកាស ដែលជម្រុញឲ្យមានបាតុភូតជាច្រើននៃអាកាសធាតុ ឬ បរិស្ថាន ដែលត្រូវបានចាត់ទុកថាមិនអាចកែប្រែបាន ឬ អាចស្តារឡើងវិញបានតែនៅក្នុងអំឡុងពេលយ៉ាងវែង ដូចជា*ផ្ទាំងថ្ម*ដែលងាប់ជាទូទៅ ឬ ការបាត់បង់ប្រព័ន្ធចរន្តទឹកមហាសមុទ្រ។

Climate variability - **វិសមរូបអាកាសធាតុ**

វិសមរូបអាកាសធាតុ សំដៅលើភាពខុសគ្នានៃស្ថានភាពជាមធ្យម និងតួលេខស្ថិតិដទៃទៀត (ដូចជា គម្លាតគំរូ ស្ថិតិនៃព្រឹត្តិការណ៍កំណាច។ល។) នៃ*អាកាសធាតុ* នៅក្នុងមាត្រដ្ឋាននៃពេលវេលា និងទីកន្លែង ហួសពីព្រឹត្តិការណ៍*ធាតុអាកាស*នីមួយៗទៅទៀត។ វិសមរូប អាចកើតឡើងដោយសារដំណើរការខាងក្នុងតាមធម្មជាតិ នៅក្នុង*ប្រព័ន្ធអាកាសធាតុ*(វិសមរូបផ្ទៃក្នុង) ឬ ភាពខុសគ្នានៃ*ថាមពលពន្លឺពីខាងក្រៅដែលកើតឡើងដោយសារសកម្មភាពមនុស្ស* ឬ ធម្មជាតិ (វិសមរូបខាងក្រៅ)។ សូមអាន*ការប្រែប្រួលអាកាសធាតុ* ។

Copenhagen Accord - **កិច្ចព្រមព្រៀងកូប៉េនហាក់**

ឯកសារមួយដែលប្រតិភូនៅក្នុងសម័យប្រជុំលើកទី ១៥នៃសន្និសីទភាគី (COP15) ក្នុងអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពី*ការប្រែប្រួលអាកាសធាតុ* បានឯកភាព“កត់សំគាល់” នៅក្នុងវគ្គពេញអង្គចុងក្រោយកាលពីថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ ២០០៩។

ទោះបី COP15 មិនបានឯកភាពក្នុងចំណោមភាគីក្នុងឧបសម្ព័ន្ធ ១ និងភាគីមិននៅក្នុងឧបសម្ព័ន្ធ ១ លើ ចំណុចដៅនៃការកាត់បន្ថយការបំភាយឧស្ម័នក៏ដោយ ការព្រមព្រៀងនេះគាំទ្រឲ្យមានការបន្ត*ពិធីសារក្យូតូ* ដោយគូស បញ្ជាក់ថា *ការប្រែប្រួលអាកាសធាតុ* គឺជាការប្រឈមធំជាងគេមួយ នៅក្នុងសម័យកាលយើងនេះ និងសង្កត់ធ្ងន់អំពី“ឆន្ទៈនយោបាយមោះមុតក្នុងការប្រយុទ្ធប្រឆាំងជាបន្ទាន់ទៅនឹង*ការប្រែប្រួលអាកាសធាតុ* អនុលោមតាមគោលការណ៍នៃការទទួលខុសត្រូវរួម ប៉ុន្តែក្នុងកម្រិតដោយឡែកពីគ្នា និងសមត្ថភាពរៀងៗខ្លួន” និងអំពាវនាវដល់រដ្ឋនានាឲ្យ“ពង្រឹងសកម្មភាព និងកិច្ចសហប្រតិបត្តិការអន្តរជាតិលើ*ការបន្សាំ* ដើម្បីកាត់បន្ថយ*ភាពងាយរងគ្រោះ* និងកសាង*ភាពធន់ទ្រាំ* នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេស នៅក្នុងបណ្តាប្រទេសដែលងាយរងគ្រោះបំផុត ជាពិសេស ប្រទេសដែលមានការអភិវឌ្ឍតិចតួច (LDCs) បណ្តារដ្ឋកំពុងអភិវឌ្ឍន៍នៅលើកូនកោះ (SIDS) និងអាហ្វ្រិក” និងឯកភាពថា “ប្រទេសជឿនលឿន ត្រូវផ្តល់ធនធានហិរញ្ញវត្ថុ បច្ចេកវិទ្យា និង*ការកសាងសមត្ថភាព* ឲ្យបានគ្រប់គ្រាន់ ដែលអាចព្យាករណ៍បាន និងដោយនិរន្តរភាព ដើម្បីគាំទ្រដល់ការអនុវត្តសកម្មភាព*បន្សាំ* នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍”។

Coping capacity - **សមត្ថភាពទប់ទល់**

មធ្យោបាយដែលប្រជាពលរដ្ឋ ឬ ស្ថាប័ននានាប្រើប្រាស់ធនធាននិងសមត្ថភាពដែលមាន ដើម្បីដោះស្រាយនឹងផលវិបាកអវិជ្ជមាន ដែលអាចនាំទៅរក*គ្រោះមហន្តរាយ*។ ជាទូទៅ ប្រការនេះពាក់ព័ន្ធនឹងការគ្រប់គ្រងធនធាន ទាំងនៅក្នុងស្ថានភាពធម្មតា ក៏ដូចជា ក្នុងអំឡុងពេលមានវិបត្តិ ឬក្នុងលក្ខខណ្ឌអវិជ្ជមានផងដែរ ។ តាមធម្មតា ការពង្រឹងសមត្ថភាពទប់ទល់គឺជាការកសាង*ភាពធន់ទ្រាំ* ដើម្បីទប់ទល់ចំពោះឥទ្ធិពលនៃ*មុខសញ្ញាគ្រោះថ្នាក់*ធម្មជាតិ ឬដែលបង្កដោយមនុស្ស។

Coping range - **កម្រិតសមត្ថភាពទប់ទល់**

កម្រិតនៃ*អាកាសធាតុ* ដែលលទ្ធផលនៃការទប់ទល់អាចផ្តល់ផលជាប្រយោជន៍ ឬ ជាផលអវិជ្ជមាន ប៉ុន្តែអាចនៅទ្រាំទ្របាន។ ហួសពីកម្រិតសមត្ថភាពទប់ទល់នេះ ការខូចខាត ឬ ការបាត់បង់ មិនអាចទ្រាំទ្របានទៀតទេ ហើយសង្គម (ឬ ប្រព័ន្ធ) ត្រូវចាត់ទុកថាងាយរងគ្រោះ។

# D.

Detection and attribution - **ការរកឃើញ និងចំណាងទាក់ទង**

ការរកឃើញអំពីការប្រែប្រួលនៃប្រព័ន្ធមួយ (ធម្មជាតិ ឬមនុស្ស) គឺជាដំណើរការដែលបង្ហាញឲ្យឃើញថា ប្រព័ន្ធនោះបានប្រែប្រួលនៅក្នុងក្របខ័ណ្ឌស្ថិតិដែលបានកំណត់ ដោយមិនផ្តល់មូលហេតុនៃការប្រែប្រួលនោះទេ។ *ចំណងទាក់ទង* នៃការប្រែប្រួលដែលបានសង្កេតឃើញណាមួយនៅក្នុងប្រព័ន្ធមួយ ដោយសារតែ*ការប្រែប្រួលអាកាសធាតុដោយសកម្មភាពមនុស្ស* តាមធម្មតាគឺជាដំណើរការដែលមានពីរដំណាក់កាល។ ទីមួយ ការប្រែប្រួលដែលសង្កេតឃើញនៅក្នុងប្រព័ន្ធនោះត្រូវតែបង្ហាញឲ្យឃើញថា ពាក់ព័ន្ធជាមួយ*ការប្រែប្រួលអាកាសធាតុ*ដែលបានសង្កេតឃើញនៅកម្រិតតំបន់ ក្នុងកម្រិត*ទំនុកចិត្ត*ជាក់លាក់មួយ។ ទីពីរ ភាគ/ចំណែកដែលវាស់បាននៃ*ការប្រែប្រួលអាកាសធាតុ*ដែលសង្កេតឃើញនៅកម្រិតតំបន់ ឬ ការប្រែប្រួលពាក់ព័ន្ធដែលបានសង្កេតឃើញនៅក្នុងប្រព័ន្ធនោះ ត្រូវតែមានចំណងទាក់ទងទៅនឹងកម្លាំងអាកាសធាតុ*បង្កដោយសកម្មភាពមនុស្ស* ក្នុងកម្រិតប្រហែលគ្នានៃទំនុកចិត្ត។ ទំនុកចិត្តក្នុងសេចក្តីអះអាង*ដែលមានចំណងទាក់ទងរួមគ្នា* ត្រូវតែទាបជាងទំនុកចិត្តនៅក្នុងជំហានណាមួយដាច់ដោយឡែកពីគ្នានៃ*ចំណងទាក់ទង* ដោយសារតែបង្គុំនៃការប៉ាន់ប្រមាណពីរដាច់គ្នាទៅតាមរូបមន្តស្ថិតិ។

**Development Scenario - សេណារីយ៉ូអភិវឌ្ឍន៍**

និន្នាការនៃការអភិវឌ្ឍដែលបានជ្រើសយក ដើម្បីផ្តល់ជាទស្សនវិស័យនៃកាលានុវត្តភាពសម្រាប់ការអភិវឌ្ឍទៅអនាគត និងផលប៉ះពាល់នៃការអភិវឌ្ឍទាំងនោះ។

**Disaster - គ្រោះមហន្តរាយ**

ការរំខានធ្ងន់ធ្ងរចំពោះមុខងាររបស់សហគមន៍ ឬ សង្គមមួយ ដែលបង្កឲ្យមានការបាត់បង់ជាទូទៅចំពោះមនុស្ស សម្ភារៈ សេដ្ឋកិច្ច ឬ បរិស្ថាន ដែលហួសកម្រិតសមត្ថភាពរបស់សហគមន៍រងគ្រោះ ឬ សង្គម ក្នុងការទប់ទល់ ដោយប្រើប្រាស់ធនធានផ្ទាល់ខ្លួន។

**Disaster risk - ហានិភ័យនៃគ្រោះមហន្តរាយ**

ការបាត់បង់អាយុជីវិត ស្ថានភាពសុខភាព ការចិញ្ចឹមជីវិត ទ្រព្យសម្បត្តិ និងសេវាកម្មនានា ដែលអាចបណ្តាលមកពីគ្រោះមហន្តរាយ ដែលអាចកើតមានចំពោះសហគមន៍ណាមួយ ឬ សង្គមមួយ នៅក្នុងអំឡុងពេលណាមួយទៅអនាគត។

**Disaster risk management - ការគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយ**

ដំណើរការជាលក្ខណៈប្រព័ន្ធនៃការប្រើប្រាស់បទដ្ឋានរដ្ឋបាល អង្គការចាត់តាំង និង ជំនាញប្រតិបត្តិការនិងសមត្ថភាព ដើម្បីអនុវត្តយុទ្ធសាស្ត្រ គោលនយោបាយ និងសមត្ថភាពទប់ទល់ដែលបានកែលម្អ ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃ*មុខសញ្ញាគ្រោះថ្នាក់* និងលទ្ធភាពនៃ*គ្រោះមហន្តរាយ*។ ពាក្យនេះគឺជាការពង្រីកពាក្យទូទៅជាងនេះមួយ "ការគ្រប់គ្រងហានិភ័យ" ដើម្បីដោះស្រាយបញ្ហាជាក់លាក់នៃហានិភ័យគ្រោះមហន្តរាយ។ ការគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយ មានគោលដៅបញ្ចៀស កាត់បន្ថយ ឬ ផ្ទេរឥទ្ធិពលអវិជ្ជមាននៃ*មុខសញ្ញាគ្រោះថ្នាក់* តាមរយៈសកម្មភាព និង វិធានការនានាសម្រាប់ទប់ស្កាត់ *កាត់បន្ថយ* និង *ការត្រៀមលក្ខណៈ*។

**Disaster risk reduction - ការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ**

គោលគំនិត និងការអនុវត្តក្នុងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ តាមរយៈកិច្ចប្រឹងប្រែងជាលក្ខណៈប្រព័ន្ធ ដើម្បីវិភាគ និងគ្រប់គ្រងកត្តាដែលជាឫសគល់នៃ*គ្រោះមហន្តរាយ* ដែលរួមទាំង តាមរយៈកាត់បន្ថយការរងឥទ្ធិពលពី *មុខសញ្ញាគ្រោះថ្នាក់* ការកាត់បន្ថយ*ភាពងាយរងគ្រោះ* របស់ប្រជាពលរដ្ឋ និងកំណែលម្អ*ការត្រៀមលក្ខណៈ* សម្រាប់ព្រឹត្តិការណ៍អវិជ្ជមាននានា។

**Downscaling - ការបង្រួមមាត្រដ្ឋាន**

វិធីមួយដើម្បីទទួលបានព័ត៌មានចាប់ពីកម្រិតមូលដ្ឋាន ដល់កម្រិតតំបន់ (១០ ដល់ ១០០ គ.ម) ដោយផ្អែកលើម៉ូដែលនៅកម្រិតមាត្រដ្ឋានធំជាង ឬ លើការវិភាគទិន្នន័យ។

**Drought - គ្រោះរាំងស្ងួត**

បាតុភូតដែលកើតមាន នៅពេលកម្រិតកំពស់ទឹកភ្លៀងមានទាបជាខ្លាំង ធៀបនឹងកម្រិតដែលបានកត់ត្រាជាធម្មតា ដែលបង្កឲ្យមានអតុល្យភាពធ្ងន់ធ្ងរនៃរបបជលសាស្ត្រ ដែលជាញឹកញាប់មានឥទ្ធិពលអវិជ្ជមានមកលើធនធានដីធ្លី និងប្រព័ន្ធផលិតកម្ម។

## E.

**Ecophysiological process - ដំណើរការអេកូសរីរសាស្ត្រ**

សារពាង្គកាយនីមួយៗឆ្លើយតបទៅនឹងវិសមរូបបរិស្ថាន ដូចជា *ការប្រែប្រួលអាកាសធាតុ* តាមរយៈដំណើរការអេកូសរីរសាស្ត្រ ដែលប្រព្រឹត្តទៅជាបន្តបន្ទាប់ និងដែលជាទូទៅ នៅក្នុងមាត្រដ្ឋានមីក្រូ ឬ កម្រិតសរីរាង្គរង។

យន្តការអេកូសរីរសាស្ត្រគូសបញ្ជាក់អំពីភាពធន់ទ្រាំនៃសារពាង្គកាយនីមួយៗ តបនឹងភាពតានតឹងនៃបរិស្ថាន និងផ្សំដោយប្រតិកម្មតបជាច្រើនបែប ដែលបង្ហាញអំពីដែនកំណត់នៃភាពធន់ទ្រាំដាច់ខាតរបស់សារពាង្គកាយនីមួយៗ ទៅនឹងលក្ខខណ្ឌនៃបរិស្ថាន។ គេអាចជ្រើកប្រតិកម្មតបនៃអេកូសរីរសាស្ត្រ ដើម្បីគ្រប់គ្រងតំបន់ភូមិសាស្ត្រសម្រាប់ប្រភេទសត្វ ឬ រុក្ខជាតិនានា។

**Ecosystem - ប្រព័ន្ធអេកូឡូស៊ី**

ប្រព័ន្ធមួយនៃសារពាង្គកាយរស់ ដែលមានអន្តរអំពើលើគ្នាទៅវិញទៅមក និងជាមួយមជ្ឈដ្ឋានរូបវន្តរបស់វា។ ព្រំប្រទល់នៃអ្វីដែលហៅថា ប្រព័ន្ធអេកូឡូស៊ីមួយ ពុំមានភាពច្បាស់លាស់ឡើយ និងអាស្រ័យលើចំណុចគោលនៃចំណាប់អារម្មណ៍ ឬ ការសិក្សា។ ដូច្នេះ វិសាលភាពនៃប្រព័ន្ធអេកូឡូស៊ីមួយអាចរាប់ចាប់ពីទីកន្លែងតូចមួយ រហូតដល់ផែនដីទាំងមូល។

**Ecosystem approach - អភិក្រមប្រព័ន្ធអេកូឡូស៊ី**

អភិក្រមប្រព័ន្ធអេកូឡូស៊ីគឺជា*យុទ្ធសាស្ត្រ*មួយ សម្រាប់ការគ្រប់គ្រងចម្រុះលើដីធ្លី ទឹក និងធនធានដែលមានជីវិត ដែលជម្រុញការអភិរក្ស និងការប្រើប្រាស់ដោយនិរន្តរភាពប្រកបដោយសមធម៌។

អភិក្រមប្រព័ន្ធអេកូឡូស៊ី ផ្អែកលើការប្រើប្រាស់វិធីសាស្ត្រសមស្របតាមបែបវិទ្យាសាស្ត្រ ដែលផ្តោតលើកម្រិតនៃឯកត្តាជីវសាស្ត្រ ដែលគ្របដណ្តប់រចនាសម្ព័ន្ធ ដំណើរការ មុខងារ និងអន្តរអំពើសំខាន់ៗ ក្នុងចំណោមសារពាង្គកាយនានា និងបរិស្ថានរបស់វា។ អភិក្រមនេះទទួលស្គាល់ថា មនុស្ស រួមនិងភាពចម្រុះនៃវប្បធម៌ គឺជាសមាសសភាគរួមមួយនៃ*ប្រព័ន្ធអេកូឡូស៊ី*ជាច្រើន។ អភិក្រមប្រព័ន្ធអេកូឡូស៊ីតម្រូវឲ្យមាន*ការគ្រប់គ្រងបែបបន្សុំ* ដើម្បីដោះស្រាយភាពស្មុគស្មាញ និងឌីណាមិកនៃប្រព័ន្ធអេកូឡូស៊ី និងអវត្តមាននៃចំណេះដឹង ឬការយល់ដឹងពេញលេញ អំពីមុខងាររបស់វា។ ចំណុចដៅជាអាទិភាពគឺការអភិរក្ស*ជីវៈចម្រុះ* និងរចនាសម្ព័ន្ធនិងមុខងារនៃប្រព័ន្ធអេកូឡូស៊ី ដើម្បីរក្សាការពារ*សេវាកម្មប្រព័ន្ធអេកូឡូស៊ី*។

**Ecosystem services - សេវាកម្មប្រព័ន្ធអេកូឡូស៊ី**

ដំណើរការ ឬមុខងារអេកូឡូស៊ី ដែលមានតម្លៃជាសាច់ប្រាក់ ឬមិនមែនសាច់ប្រាក់ សម្រាប់បុគ្គល ឬសង្គមជាទូទៅ។

សេវា ទាំងនោះគឺ (១) សេវាកម្មទ្រទ្រង់ ដូចជា ផលិតភាព ឬ ការថែរក្សា*ជីវៈចម្រុះ* (២) សេវាកម្មផ្គត់ផ្គង់ ដូចជា ចំណីអាហារ រុក្ខជាតិសរសៃ ឬ ត្រី (៣) សេវាកម្មនិយ័តកម្ម ដូចជា ការពារទឹកជំនន់ និយ័តកម្ម*អាកាសធាតុ* ឬ *សម្រូបកាបូន* និង (៤) សេវាកម្មវប្បធម៌ ដូចជា ទេសចរណ៍ ឬ ការឲ្យតម្លៃខាងស្មារតី និងសោភណ្ឌភាព។

**El Niño-Southern Oscillation (ENSO) - ចរន្តទឹកក្តៅអែលនីញ៉ូខាងត្បូង**

អែលនីញ៉ូ តាមអត្ថន័យដើម គឺជាចរន្តទឹកក្តៅ ដែលហូរជាទៀងទាត់ តាមឆ្នេរសមុទ្រនៅអេក្វាទ័រ និងប៉េរូ ដែលរំខានដល់ការនេសាទនៅក្នុងមូលដ្ឋាន។ ព្រឹត្តិការណ៍ក្នុងមហាសាគរបែបនេះ មានការពាក់ព័ន្ធជាមួយការប្រែប្រួលនៃទម្រង់សម្ពាធបរិយាកាសក្នុងតំបន់ត្រូពិក និងចរន្តទឹកនៅក្នុងមហាសាគរឥណ្ឌា និងប៉ាស៊ីហ្វិក ដែលហៅថា ចរន្តទិសខាងត្បូង។ បាតុភូតនេះ រួមផ្សំជាមួយបាតុភូត*បរិយាកាស*-មហាសមុទ្រ ត្រូវគេហៅរួមគ្នាថា ចរន្តទឹកក្តៅខាងត្បូង។

នៅក្នុងអំឡុងពេលនៃព្រឹត្តិការណ៍អែលនីញ៉ូ ចរន្តខ្យល់ភាគច្រើនដែលជាខ្យល់បណ្តូរ បានចុះខ្សោយ ចំណែកចរន្តខ្យល់តាមទិសប្រាសមកពីអេក្វាទ័រ កាន់តែមានឥទ្ធិពលខ្លាំងឡើង ដែលបង្កឲ្យផ្ទៃលើនៃទឹកសមុទ្រនៅតំបន់ឥណ្ឌូនេស៊ីឡើងក្តៅ និងហូរទៅទិសខាងកើត នៅពីលើចរន្តទឹកត្រជាក់នៅប៉េរូ។ ព្រឹត្តិការណ៍នេះមានផលប៉ះពាល់យ៉ាងធំធេងមកលើចរន្តខ្យល់ សីតុណ្ហភាពទឹកនៅផ្ទៃខាងលើ និងរបបទឹកភ្លៀងនៅក្នុងមហាសមុទ្រប៉ាស៊ីហ្វិកត្រង់តំបន់ត្រូពិក។ វាជាឥទ្ធិពលអាកាសធាតុនៅទូទាំងតំបន់ប៉ាស៊ីហ្វិក និងក្នុងតំបន់ជាច្រើនផ្សេងទៀតនៃពិភពលោក។ ព្រឹត្តិការណ៍ដែលផ្ទុយពីអែលនីញ៉ូ គឺឡានីញ៉ា។

**Emission scenario - សេណារីយ៉ូនៃការបំភាយ**

ការបង្ហាញជាតំណាងឲ្យការវិវត្តទៅអនាគតនៃការបំភាយសារធាតុនានា ដែលមានសក្តានុពលបញ្ចេញកាំរស្មីសកម្ម (ដូចជា *ឧស្ម័នផ្ទះកញ្ចក់ អាអេរ៉ូសូល*) ដោយផ្អែកលើការសន្មតិមួយឈុតនៃកម្លាំងជម្រុញ ដែលមានសង្គតិភាព និងស៊ីសង្វាក់គ្នា (ដូចជា ការវិវត្តនៃប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម ការប្រែប្រួលបច្ចេកវិទ្យា) និងទំនាក់ទំនងគន្លឹះនៃកត្តាទាំងនោះ។ នៅឆ្នាំ ១៩៩២ *IPCC* បានបង្ហាញសេណារីយ៉ូនៃការបំភាយ ដែលត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់*និទស្សន៍អាកាសធាតុ* នៅក្នុងរបាយការណ៍ប៉ាន់ប្រមាណលើកទីពីរ។ សេណារីយ៉ូនៃការបំភាយទាំងនេះ ត្រូវបានកត់សំគាល់ថាជា *សេណារីយ៉ូ* IS92។ នៅក្នុងរបាយការណ៍ពិសេសរបស់ *IPCC* ស្តីពីសេណារីយ៉ូនៃការបំភាយ (*SRES*) (យោងតាម Nakic´enovié et al., 2000) មានការចេញផ្សាយសេណារីយ៉ូបំភាយថ្មីៗ ដែលគេឲ្យឈ្មោះថា សេណារីយ៉ូ SRES។

**Ensemble - សំណុំ**

ម៉ូដែលស្របគ្នាមួយក្រុម ដែលបានប្រើប្រាស់សម្រាប់*និទស្សន៍អាកាសធាតុ* ។

ភាពខុសគ្នានៃលទ្ធផលនៅទូទាំងសមាសភាពនៃសំណុំនេះ ផ្តល់នូវការប៉ាន់ប្រមាណអំពី*ភាពមិនប្រាកដប្រជា។* សំណុំដែលផ្សំឡើងពីម៉ូដែលដូចគ្នា ប៉ុន្តែមានលក្ខខណ្ឌដំបូងខុសគ្នា បានត្រឹមតែបង្ហាញពីចរិតលក្ខណៈនៃ*ភាពមិនប្រាកដប្រជា* ដែលពាក់ព័ន្ធជាមួយ*វិសមភាពអាកាសធាតុ*ផ្ទៃក្នុង ចំណែកសំណុំនៃពហុម៉ូដែល ដែលរួមទាំង ប្រតិបត្តិការនៃម៉ូដែលមួយចំនួន ក៏គិតគូរផងដែរអំពីវិភាគទាននៃភាពខុសគ្នាក្នុងចំណោមម៉ូដែលទាំងនេះ ដែលទាក់ទងនឹង*ភាពមិនប្រាកដប្រជា*។

**Evaporation - រំហួត**

ដំណើរការអន្តរកាលនៃការប្រែធាតុពីសារធាតុរាវ ទៅជាឧស្ម័ន។

**Evapotranspiration - រំហួតនិងកំណកជាញើស**

ដំណើរការរួមគ្នានៃ*រំភាយ*ចំហាយទឹក ពីផ្ទៃផែនដី និង*កំណកជាញើស*ពីសំណាក់រុក្ខជាតិ។

**External forcing - កម្លាំង/កត្តាខាងក្រៅ**

កម្លាំងខាងក្រៅ សំដៅលើកម្លាំងនៃកត្តាពីខាងក្រៅ*ប្រព័ន្ធអាកាសធាតុ* ដែលបង្កឲ្យមានការប្រែប្រួលនៃ*ប្រព័ន្ធអាកាសធាតុ*។ បន្ទុះភ្នំភ្លើង វិសមរូបនៃពន្លឺព្រះអាទិត្យ និងការប្រែប្រួលដោយសារសកម្មភាពមនុស្ស មកលើសមាសភាពនៃ*បរិយាកាស* និង*ការប្រែប្រួលនៃការប្រើប្រាស់ដី* គឺជាកម្លាំងខាងក្រៅ។

**Extreme weather event - ព្រឹត្តិការណ៍ធាតុអាកាសកំណាច**

ព្រឹត្តិការណ៍មួយ ដែលមានដោយកម្រ នៅក្នុងរបាយទិន្នន័យស្ថិតិយោង តាមទីកន្លែងណាមួយជាក់លាក់។ និយមន័យនៃពាក្យ"កម្រ" មានភាពខុសប្លែកគ្នា ប៉ុន្តែព្រឹត្តិការណ៍ធាតុអាកាសកំណាច តាមធម្មតាវាកើតឡើងក្នុងកម្រិត"កម្រ" ក្នុងកម្រិត១០% ឬ ៩០% ឬ ឬកម្រជាងនេះទៅទៀត។ បើគិតតាមនិយមន័យ សំណុំលក្ខណៈអំពីអ្វីដែលហៅថា "ធាតុអាកាសកំណាច" អាចមានភាពខុសគ្នារវាងកន្លែងនានា។ ជាទូទៅ ព្រឹត្តិការណ៍ធាតុអាកាសកំណាច អាចរាប់បញ្ចូល *ទឹកជំនន់* និង *គ្រោះរាំងស្ងួត*។

## F.

**Flood – ទឹកជំនន់**

វត្តមានទឹកក្នុងបរិមាណយ៉ាងច្រើនដែលហូរហៀរទៅក្នុងកន្លែងដែលពីមុនមកស្ងួត។ ទឹកជំនន់ រួមមានជំនន់ទឹកទន្លេ ជំនន់គង្ហក់ ជំនន់ទីក្រុង ជំនន់ទឹកភ្លៀង ជំនន់ពីលូទឹកស្អុយ ជំនន់តំបន់ឆ្នេរ និង ជំនន់ពីការលោយទឹកកក[1]។

*ការប្រែប្រួលអាកាសធាតុ* ត្រូវបាននិទស្សន៍ថា នាំឲ្យមានកំណើនការធ្លាក់ភ្លៀងជាច្រើននៅក្នុងតំបន់មេគង្គ ក៏ដូចជា រំពឹងថាកើនឡើងផងដែរ ដែលនាំឲ្យមានកំណើន ប្រពលភាពនៃការធ្លាក់ភ្លៀង។ ដូច្នេះ ទឹកជំនន់នឹងអាចកើតមានកាន់តែញឹកញាប់ និងកាន់តែខ្លាំងផងដែរ។

**Food security - សន្តិសុខស្បៀង**

ស្ថានភាពមួយដែលកើតឡើង នៅពេលដែលពលរដ្ឋមានលទ្ធភាពក្នុងការធានាថាអាចទទួលស្បៀងក្នុងបរិមាណប្រកបដោយសុវត្ថិភាព និងអាហារូបត្ថម្ភគ្រប់គ្រាន់សម្រាប់ការលូតលាស់ ការអភិវឌ្ឍ និងជីវិតរស់នៅសកម្ម និងសុខភាពល្អជាធម្មតា។ អសន្តិសុខស្បៀង អាចបង្កឡើង ដោយសារតែអវត្តមានស្បៀង គ្មានលទ្ធភាពគ្រប់គ្រាន់ក្នុងការទិញ ការបែងចែកមិនសមស្រប ឬ ការប្រើប្រាស់ស្បៀងមិនបានត្រឹមត្រូវនៅក្នុងគ្រួសារ។

---

[1] http://www.ipcc.ch/organization/organization.shtml#.UVzmXKLwnw0

## G.

**Glacier - ផែនទឹកកក**

ម៉ាសនៃដែនដីដែលមានទឹកកកហូរចុះតាមជម្រាលភ្នំ (ដោយសារតែការប្រែសណ្ឋាននៅខាងក្នុង និងរអិលចុះមកខាងក្រោម) និងរារាំងដោយសណ្ឋានដីនៅជុំវិញ (ដូចជា បរិវេណនៃជ្រលងភ្នំ ឬ កំពូលខ្ពស់ៗនៅជុំវិញ)។ ផែនទឹកកកមួយកន្លែង មានអត្ថិភាពបានអាស្រ័យដោយការចាក់បង្គរនៃទឹកកកសំឡីនៅក្នុងទីដែលមានរយៈកំពស់ខ្ពស់ និងមានតុល្យភាពជាមួយការរលាយនៅរយៈកំពស់ទាប ឬ ការហូរចេញទៅក្នុងសមុទ្រ។

**Global warming - ការឡើងកំដៅផែនដី**

ការឡើងកំដៅផែនដី សំដៅលើកំណើនជាបណ្តើរៗ ដែលអាចសង្កេតដឹង ឬ ធ្វើនិទស្សន៍បាន នៃសីតុណ្ហភាពនៅផ្ទៃលើនៃផែនដី ដែលជាផលវិបាកមួយនៃ*កម្លាំងកាំរស្មី* ដោយសារតែ*ការបំភាយពីសកម្មភាពមនុស្ស*។

**Global Warming Potential (GWP) - សក្តានុពលកំដៅពិភពលោក**

ផ្អែកតាមសំណុំលក្ខណៈនៃ*កាំរស្មី* ដែលបានពីល្បាយស្មើសាច់នៃ*ឧស្ម័នផ្ទះកញ្ចក់* សក្តានុពលកំដៅពិភពលោក គឺជាសន្ទស្សន៍មួយនៃរង្វាស់*កម្លាំងកាំរស្មី* ក្នុងមួយឯកត្តាម៉ាសល្បាយស្មើសាច់នៃ*ឧស្ម័នផ្ទះកញ្ចក់* នៅក្នុង*បរិយាកាស*បច្ចុប្បន្ននេះ ដែលគិតនៅក្នុងអំឡុងពេលណាមួយ ធៀបទៅនឹង*កម្លាំងកាំរស្មី* នៃម៉ាសដែលបានពី*ឧស្ម័នកាបូនិក*។ GWP តំណាងឲ្យឥទ្ធិពលរួមគ្នានៅក្នុងពេលខុសៗគ្នាដែលឧស្ម័នទាំងនេះនៅក្នុង*បរិយាកាស* និងប្រសិទ្ធភាពធៀបនៃឧស្ម័នទាំងនេះក្នុងការស្រូបយក*កាំរស្មីអាំងប្រាកំដៅ* ដែលភាយចេញ។ *ពិធីសារក្យូតូ* បានផ្អែកលើ GWPs ដែលបានពីការបំភាយនៅក្នុង រយៈពេល១០០ ឆ្នាំ។

**Greenhouse effect – ផលផ្ទះកញ្ចក់**

ដំណើរការដែលក្នុងនោះ*បរិយាកាស*ស្រូបយក*កាំរស្មីអាំងប្រា* ដែលធ្វើឲ្យផែនដីឡើងកំដៅ។ នៅក្នុងការសន្ទនាជាធម្មតាពាក្យ"ផលផ្ទះកញ្ចក់" អាចយកមកប្រើប្រាស់ ដោយសំដៅលើ ផលដែលកើតចេញពីឧស្ម័នផ្ទះកញ្ចក់ធម្មជាតិ ដោយសារតែ*ឧស្ម័នផ្ទះកញ្ចក់*ដែលកើតឡើងដោយធម្មជាតិ ឬយោងទៅផលផ្ទះកញ្ចក់បន្ថែម(*បណ្តាលពីសកម្មភាពមនុស្ស*) ដែលកើតចេញពីឧស្ម័នដែលភាយជាលទ្ធផលនៃសកម្មភាពរបស់មនុស្ស។

**Greehouse gas (GHG) - ឧស្ម័នផ្ទះកញ្ចក់**

**ជា**សំណុំនៃឧស្ម័ននានា ដែលមាននៅក្នុងបរិយាកាស ដែលកើតឡើងដោយធម្មជាតិ និង*ពីសកម្មភាពរបស់មនុស្ស* ដែលស្រូប និងបញ្ចេញកាំរស្មីតាមជំហានរលកជាក់លាក់ នៅក្នុងបាច់ពន្លឺនៃ*កាំរស្មីអាំងប្រា* ដែលភាយចេញពីផ្ទៃផែនដី ពី*បរិយាកាស* និងពីពពក។ សំណុំលក្ខណៈនេះ បង្កឲ្យមាន*ផលផ្ទះកញ្ចក់*។

ចំហាយទឹក ($H_2O$) *ឧស្ម័នកាបូនិក* ($CO_2$) ឌីអាសូតម៉ូណូអុកស៊ីត($N_2O$) មេតាន ($CH_4$)និង*អូហ្សូន* ($O_3$) គឺជាឧស្ម័នផ្ទះកញ្ចក់ចំបងៗនៅក្នុង*បរិយាកាស* នៃផែនដី។

## H.

### Hazard - **មុខសញ្ញាគ្រោះថ្នាក់**

បាតុភូត សារធាតុ សកម្មភាពមនុស្ស ឬលក្ខខណ្ឌគ្រោះថ្នាក់ណាមួយ ដែលអាចបង្កឲ្យមានការបាត់បង់អាយុជីវិត រងរបួស ឬ ផលប៉ះពាល់ផ្សេងទៀតមកលើសុខភាព ខូចខាតទ្រព្យសម្បត្តិ បាត់បង់របរចិញ្ចឹមជីវិត និងសេវាកម្ម ដែលរំខានដល់ដំណើរការសង្គមនិងសេដ្ឋកិច្ច ឬ ខូចខាតចំពោះបរិស្ថាន។

## I.

### Ice cap - **គម្របទឹកកក**

ម៉ាសទឹកកកដែលមានសណ្ឋាណជាសាជី គ្របពីលើទីខ្ពស់ ដែលមានវិសាលភាពតូចជាខ្លាំងធៀបនឹង*ផែនទឹកកក*។

### Ice sheet - **ដែនដីទឹកកក**

ម៉ាសដែនដីទឹកកកដែលមានជម្រៅគ្រប់គ្រាន់ ដែលអាចគ្របដណ្តប់សណ្ឋានដីនៃស្រទាប់សិលានៅពីខាងក្រោម។ ទឹកកក រលាយនិងហូរចេញ ពីខ្ពង់រាបកណ្តាលនៃដែនដីនេះ ដែលផ្ទៃលើមានចំណោតជាមធ្យម។ ជាយខាងក្រៅមានចំណោតខ្លាំង ហើយទឹកកករលាយ និងហូរយ៉ាងលឿនតាមស្ទឹងទឹកត្រជាក់ ឬនៅក្នុងករណីខ្លះតាមច្រកនៃ*ដែនដីទឹកកក* ចាក់ចូលទៅក្នុងសមុទ្រ ឬ ចាក់ចូលទៅក្នុងផែនទឹកកកដែលអណ្តែតនៅលើផ្ទៃសមុទ្រ។ នៅក្នុងសម័យកាលទំនើបនេះ មានដែនដីទឹកកកតែពីរទេពោលគឺ ហ្គ្រីនលែន និងអង់តាកទិក។ ដែនដីទឹកកកអង់តាកទិក ត្រូវបានចែកចេញជាភាគខាងកើតនិងខាងលិច ដោយសារជួរភ្នំត្រង់អង់តាកទិក។ ក្នុងអំឡុងយុគទឹកកក មានដែនដីទឹកកកផ្សេងក្រៅពីនេះផងដែរ។

### (climate change) Impact assessment - **ការវាយតម្លៃហេតុប៉ះពាល់ (នៃការប្រែប្រួលអាកាសធាតុ)**

ការអនុវត្តដែលកំណត់អត្តសញ្ញាណ និងវាយតម្លៃ គិតជាទឹកប្រាក់ និង/ឬ មិនមែនទឹកប្រាក់ នូវឥទ្ធិពលនៃ*ការប្រែប្រួលអាកាសធាតុ* មកលើប្រព័ន្ធធម្មជាតិ និងប្រព័ន្ធមនុស្ស។

### (climate change) Impacts - **ផលប៉ះពាល់ (នៃការប្រែប្រួលអាកាសធាតុ)**

ផលវិបាកនានានៃ*ការប្រែប្រួលអាកាសធាតុ* មកលើប្រព័ន្ធធម្មជាតិ និងមនុស្ស។ អាស្រ័យលើការពិចារណាអំពី*ការបន្សាំ* គេអាចញែកភាពខុសគ្នារវាងផលប៉ះពាល់ដែលអាចកើតមាន និងផលប៉ះពាល់ដែលបន្សល់ទុក។

- **ផលប៉ះពាល់ដែលអាចកើតមាន៖** ផលប៉ះពាល់ទាំងអស់ដែលអាចកើតឡើង ដោយសារតែការប្រែប្រួលអាកាសធាតុដែលបាននិទស្សន៍ ដោយមិនគិតអំពី*ការបន្សាំ*។
- **ផលប៉ះពាល់ដែលបន្សល់ទុក៖** ផលប៉ះពាល់ពី*ការប្រែប្រួលអាកាសធាតុ*ដែលអាចកើតឡើងនៅក្រោយមាន*ការបន្សាំ*។ សូមអាន *ផលប៉ះពាល់សរុប* ផលប៉ះពាល់នៃទីផ្សារ និងផលប៉ះពាល់មិនមែនទីផ្សារ។
- **ផលប៉ះពាល់សរុប៖** ផលប៉ះពាល់សរុបពីការបូករួមរវាងវិស័យនានា និង/ឬ តំបន់នានា។ ការបូកសរុបផលប៉ះពាល់បែបនេះទាមទារឲ្យមានចំណេះដឹង(ឬ ការសន្មតិ)អំពីសារៈសំខាន់ធៀបនៃផលប៉ះពាល់នៅក្នុងវិស័យ និងតំបន់ខុសៗគ្នា។ រង្វាស់អំពីផលប៉ះពាល់សរុប រួមមាន ដូចជា ចំនួនជនរងគ្រោះសរុប ការប្រែប្រួលនៃផលិតភាពបឋមសរុប ចំនួនប្រព័ន្ធដែលស្ថិតក្រោមការប្រែប្រួល ឬ ការបង់ខាតសេដ្ឋកិច្ចសរុប។

- **ផលប៉ះពាល់ទីផ្សារ៖** ផលប៉ះពាល់ដែលផ្សារភ្ជាប់ទៅនឹងប្រតិបត្តិការនៃទីផ្សារ និងដែលមានឥទ្ធិពលដោយផ្ទាល់មកលើ*ផលទុនក្នុងស្រុកសរុប (GDP)* ដូចជា ការប្រែប្រួលនៃការផ្គត់ផ្គង់ និងថ្លៃផលិតផលកសិកម្ម។
- **ផលប៉ះពាល់មិនមែនទីផ្សារ៖** ផលប៉ះពាល់ដែលមានឥទ្ធិពលមកលើប្រព័ន្ធអេកូឡូស៊ី ឬ *សុខុមាលភាព*មនុស្ស ប៉ុន្តែមិនផ្សារភ្ជាប់ដោយផ្ទាល់ទៅនឹងប្រតិបត្តិការខាងទីផ្សារឡើយ ដូចជាកំណើនហានិភ័យនៃការបាត់បង់ជីវិតពីរយៃក្មេង។

Industrial revolution - **បដិវត្តន៍ឧស្សាហកម្ម**

អំឡុងពេលមួយនៃការលូតលាស់ឧស្សាហកម្មឆាប់រហ័ស ដោយនាំមកនូវផលវិបាកយ៉ាងច្រើនខាងផ្នែកសង្គម និង សេដ្ឋកិច្ច ដោយចាប់ផ្ដើមពីអង់គ្លេសនៅក្នុងអំឡុងពាក់កណ្ដាលចុងក្រោយនៃសតវត្សរ៍ទី ១៨ និងរីកសាយទៅអឺរ៉ុប និងក្រោយមកទៅប្រទេសផ្សេងទៀត ដែលរួមទាំងស.រ.អា។

បដិវត្តន៍ឧស្សាហកម្មកត់សំគាល់នូវការចាប់ផ្ដើមនៃកំណើនយ៉ាង ខ្លាំងក្លានៃចំហេះឥន្ធនៈផូស៊ីល និងការបំភាយ*ឧស្ម័នកាបូនិក*ដែលពាក់ព័ន្ធ។ នៅក្នុងរបាយការប៉ាន់ប្រមាណលើកទីបួនរបស់ *IPCC* ចាប់ពីឆ្នាំ ២០០៧មក ពាក្យថា "មុន-ឧស្សាហកម្ម" សំដៅលើចន្លោះពេលប្រហែលនៅមុនឆ្នាំ ១៧៥០។

Infrared radiation - **កាំរស្មីអាំងប្រា**

ថាមពលកំដៅដែលភាយចេញពីគ្រប់វត្ថុរឹង រាវ និងឧស្ម័ន។

នៅក្នុងបរិបទនៃបញ្ហាផ្ទះកញ្ចក់ ពាក្យនេះសំដៅលើថាមពលកំដៅ ដែលភាយចេញពីផ្ទៃផែនដី និង*បរិយាកាស*នៃផែនដី។ ឧស្ម័នផ្ទះកញ្ចក់ ស្រូបកាំរស្មីជាច្រើននៅក្នុង*បរិយាកាស*នៃផែនដី និងភាយចេញកាំរស្មីខ្លះត្រឡប់មកផ្ទៃផែនដីវិញ ដែលបង្កើតជា*ផលផ្ទះកញ្ចក់*។

Integrated assessment - **ការប៉ាន់ប្រមាណចម្រុះ**

ដំណើរការពហុជំនាញនៃការរួមផ្សំ វិភាគ បកស្រាយ និងប្រាស្រ័យទាក់ទងចំណេះដឹងដែលបានពីមុខវិជ្ជាវិទ្យាសាស្ត្រខុសៗគ្នា ដើម្បីអាចវាយតម្លៃ និងពិចារណាគ្រប់ទិដ្ឋភាពដែលពាក់ព័ន្ធនៃបញ្ហាស្មុគស្មាញរបស់សង្គម សម្រាប់ជាប្រយោជន៍នៃការធ្វើសេចក្ដីសម្រេច។

Intergovernmental Panel on Climate Change (IPCC) - **ក្រុមការងារអន្តររដ្ឋាភិបាលស្ដីពីការប្រែប្រួលអាកាសធាតុ**

ក្រុមការងារអន្តររដ្ឋាភិបាលស្ដីពីការប្រែប្រួលអាកាសធាតុ (IPCC) គឺជាអង្គភាពអន្តរជាតិនាំមុខសម្រាប់ការប៉ាន់ប្រមាណអំពី*ការប្រែប្រួលអាកាសធាតុ*។ អង្គភាពនេះបានបង្កើតឡើងដោយកម្មវិធីបរិស្ថានសហប្រជាជាតិ (UNEP) និងអង្គការឧតុនិយមពិភពលោក (WMO) ដើម្បីផ្ដល់ឲ្យពិភពលោកនូវទស្សនៈវិទ្យាសាស្ត្រច្បាស់លាស់អំពីស្ថានភាពបច្ចុប្បន្ននៃចំណេះដឹងអំពី*ការប្រែប្រួលអាកាសធាតុ* និងផលប៉ះពាល់បរិស្ថាន និងសង្គម-សេដ្ឋកិច្ចដែលអាចកើតឡើង[2]។

[2] http://www.ipcc.ch/organization/organization.shtml#.UV0NEqLwnw0

J.

K.

Kyoto Protocol - **ពិធីសារក្យូតូ**

ពិធីសារក្យូតូ គឺជាកិច្ចព្រមព្រៀងអន្តរជាតិមួយ ដែលជាប់ទាក់ទងទៅនឹង អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ដែលចង់ភ្ជាប់ភាគីទាំងឡាយរបស់ខ្លួន តាមរយៈការបង្កើតគោលដៅកាត់បន្ថយការបញ្ចេញឧស្ម័នរួម គ្នាថ្នាក់អន្តរជាតិមួយ[3] ។

L.

La Niña - **ឡានីញ៉ា**

សូមអាន *ចរន្តអែលនីញ៉ូទិសខាងត្បូង (ENSO)*

M.

(climate change) Mainstreaming - **ការបញ្ជ្រាប (ការប្រែប្រួលអាកាសធាតុ)**

ផលប៉ះពាល់ដែលអាចកើតឡើងបណ្តាលមកពី*ការប្រែប្រួលអាកាសធាតុ* ត្រូវបានពិចារណា ហើយវិធានការ*បន្សុាំ*សមស្រប ត្រូវបានដាក់បញ្ចូលជាទម្លាប់អនុវត្តធម្មតា នៅក្នុងសកម្មភាពនៃកម្មវិធីជាប្រចាំ។

Maladaptation - **ការបន្សុាំមិនត្រឹមត្រូវ**

រាល់ការប្រែប្រួលនៃប្រព័ន្ធធម្មជាតិ និងប្រព័ន្ធមនុស្ស ដែលនាំឲ្យមានកំណើន*ភាពងាយរងគ្រោះ* ចំពោះមុខ*កត្តាជម្រុញនៃអាកាសធា*តុនិងដែលមិនមែនកើតឡើងដោយចេតនា។ *ការបន្សុាំ* ដែលមិនបានទទួលជោគជ័យក្នុងការកាត់បន្ថយ ប៉ុន្តែនាំឲ្យមានកំណើន*ភាពងាយរងគ្រោះ* ទៅវិញ។

Microclimate - **មីក្រូអាកាសធាតុ**

អាកាសធាតុនៅមូលដ្ឋានត្រង់ផ្ទៃផែនដី ឬ នៅជិតផ្ទៃផែនដី។ សូមអាន *អាកាសធាតុ*។

(climate change) Mitigation **ការកាត់បន្ថយ (ការប្រែប្រួលអាកាសធាតុ)**

អន្តរាគមន៍*របស់មនុស្ស* ដើម្បីកាត់បន្ថយកត្តានាំមុខបណ្តាលពី*សកម្មភាពមនុស្ស* នៅក្នុង*ប្រព័ន្ធអាកាសធាតុ។* អន្តរាគមន៍ទាំងនេះរាប់បញ្ចូល យុទ្ធសាស្ត្រនានា ដើម្បីកាត់បន្ថយប្រភព និងការបំភាយ*ឧស្ម័នផ្ទះកញ្ចក់* និងបង្កើនសម្រួប*ឧស្ម័នកាបូនិក*។ សូមអាន *អាងស្រូបកាបូន*។

[3] http://unfccc.int/kyoto_protocol/items/2830.php

**Mitigation potential - សក្តានុពលកាត់បន្ថយ**

នៅក្នុងបរិបទនៃ*ការកាត់បន្ថយការប្រែប្រួលអាកាសធាតុ* សក្តានុពលនៃការកាត់បន្ថយគឺជាបរិមាណនៃ*ការកាត់បន្ថយ* ដែលអាចសម្រេចបាន ប៉ុន្តែនៅពុំទាន់បានអនុវត្តនៅឡើយ។

**Monsoon - ខ្យល់មូសុង**

ម៉ូសុងគឺជាដំណើរច្រាសត្រឡប់មកវិញប្រចាំរដូវនៅក្នុងតំបន់ត្រូពិក និងក្បែរត្រូពិក នៃខ្យល់នៅជិតផ្ទៃផែនដី និងការធ្លាក់ភ្លៀងដែលពាក់ព័ន្ធជាមួយគ្នានេះ។

## N.

**National Action Plan - ផែនការសកម្មភាពជាតិ**

ឯកសារជាតិមួយដែលចែងអំពីផែនការសកម្មភាពដើម្បីដោះស្រាយបញ្ហា និងកិច្ចការនានា ដែលប្រព័ន្ធមនុស្ស ការអភិវឌ្ឍសេដ្ឋកិច្ច និងបរិស្ថានជាក់លាក់ណាមួយជួបប្រឈម។

**National Adaptation Programmes of Action (NAPAs) - កម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ**

ឯកសារដែលប្រទេសអភិវឌ្ឍន៍តិចតួច (LDCs) រៀបរៀងឡើង ដើម្បីកំណត់អត្តសញ្ញាណសកម្មភាពបន្ទាន់ និងចំពោះមុខ ដែលមានប្រយោជន៍សម្រាប់ទប់ទល់នឹង*ការប្រែប្រួលអាកាសធាតុ*។ បន្ទាប់មក ឯកសារ NAPAsនឹងត្រូវបង្ហាញជូនទៅសហគមន៍អន្តរជាតិ ដើម្បីសុំការគាំទ្រ។

**National Target Programme (NTP) - កម្មវិធីចំណុចដៅជាតិ**

ឯកសារជាតិនៃប្រទេសវៀតណាម ដែលចែងអំពី*ផលប៉ះពាល់*ហានិភ័យសំខាន់ៗនៃ*ការប្រែប្រួលអាកាសធាតុ* និងសកម្មភាពអាទិភាព ដើម្បី*ឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ*។

**No-regrets policy - គោលនយោបាយមិនស្តាយក្រោយ**

គោលនយោបាយមួយដែលអាចបង្កើតផលប្រយោជន៍សង្គម និង/ឬ សេដ្ឋកិច្ចច្រើនជាងការបង់ខាត បើទោះជា*ការប្រែប្រួលអាកាសធាតុដោយសារសកម្មភាពមនុស្ស* កើតឡើង ឬ មិនកើតឡើងក៏ដោយ។

**Non-linearity - ភាពមិនត្រង់/មិនរលូន/មិនលីនេអ៊ែរ**

ដំណើរការមួយត្រូវបានហៅថា "មិនត្រង់" នៅពេលដែលពុំមានទំនាក់ទំនងសមាមាត្រងាយ រវាងហេតុនិងផល។

## O.

**Opportunity costs - ថ្លៃឱកាស**

ថ្លៃសកម្មភាពសេដ្ឋកិច្ចដែលបានបាត់បង់ ដោយសារការជ្រើសយកសកម្មភាពផ្សេងទៀត។

Ozone - **អូហ្សូន**

ទម្រង់នៃអុកស៊ីសែនដែលមានអាតូមចំនួនបី ($O_3$)ពោលគឺ ឧស្ម័នដែលមានផ្សំនៅក្នុងបរិយាកាស។

នៅក្នុង*ត្រូប៉ូស្វ៊ែរ* ឧស្ម័ននេះបានកើតឡើងដោយធម្មជាតិ និងដោយសារប្រតិកម្មហ្វូតូគីមី ដែលពាក់ព័ន្ធនឹងឧស្ម័ននានា ដែលកើតចេញពី សកម្មភាពមនុស្ស (*ស្ម៉ុកហ្វូតូគីមី*) ។ ពេលមានកំហាប់ខ្ពស់ អូហ្សូននៅក្នុងត្រូប៉ូស្វ៊ែរអាចបង្កគ្រោះថ្នាក់ ដល់សារពាង្គកាយមានជីវិតជាច្រើន។ អូហ្សូននៅក្នុងត្រូប៉ូស្វ៊ែរដើរតួជា *ឧស្ម័នផ្ទះកញ្ចក់* ។ នៅក្នុងស្ត្រាតូស្វ៊ែរ អូហ្សូនបាន កើតឡើងតាមរយៈ អន្តរអំពើរវាងកាំរស្មីស្វាយអ៊ុលត្រាពីព្រះអាទិត្យ និងម៉ូលេគុលអុកស៊ីហ្សែន ($O_2$)។

Ozone depletion - **ការបាត់បង់ស្រទាប់អូហ្សូន**

ការបាត់បង់ស្រទាប់អូហ្សូននៅក្នុងស្ត្រាតូស្វ៊ែរ ដោយសារតែប្រតិកម្មគីមី ដែលអាចកើតឡើងពី*ការប្រែប្រួលអាកាសធាតុ* ដែលនាំឲ្យមានកំណើនចំណាំងចូលនៃកាំរស្មីស្វាយអ៊ុលត្រា B នៅស្រទាប់ក្រោម។

## P.

Permafrost - **មណ្ឌលកក**

ផ្ទៃដី (ដី ឬ ថ្ម និងរួមបញ្ចូល ទឹកកក និងសារធាតុសរីរាង្គ) ដែលនៅត្រឹម 0°C ឬ ទាបជាងនេះ យ៉ាងហោចណាស់រយៈ ពេលពីរឆ្នាំជាប់គ្នា។

Phenology - **បាតុភូតវិទ្យា**

ការសិក្សាអំពីបាតុភូតធម្មជាតិ ដែលកើតឡើងជាទៀងទាត់ (ដូចជា ដំណាក់កាលអភិវឌ្ឍន៍ ចរាចរតាមរដូវ) និងទំនាក់ ទំនងរបស់វាទៅនឹង *អាកាសធាតុ* និងការប្រែប្រួលតាមរដូវ។

Phenotypic plasticity - **ភាពបត់បែនបាននៃផេណូទីប**

សមត្ថភាពនៃសារពាង្គកាយមួយ ក្នុងការបន្សាំទៅនឹងបរិស្ថានដែលប្រែប្រួល តាមរយៈការកែប្រែផេណូទីបរបស់វា ដោយ គ្មានកែប្រែសេណូទីបរបស់វា។

Physiographic - **ក្រាហ្វិកសេរីសាស្ត្រ**

ដែលទាក់ទង ឬ ដែលប្រើប្រាស់ សេចក្ដីអធិប្បាយមួយអំពីធម្មជាតិ ឬ អំពីបាតុភូតធម្មជាតិ។

Potential production - **សក្ដានុពលនៃការផលិត**

ផលិតភាពដំណាំដែលបានប៉ាន់ស្មាន នៅក្រោមលក្ខខណ្ឌដី សារធាតុចិញ្ចឹម និងទឹក ដែលគ្មានដែនកំណត់។

(Disaster) Preparedness - **ការត្រៀមបង្ការ(គ្រោះមហន្តរាយ)**

ចំណេះដឹង និងសមត្ថភាព ដែលបង្កើតឡើងដោយរដ្ឋាភិបាល ដោយតាមការឆ្លើយតបតាមវិជ្ជាជីវៈ និងដោយការងារស្តារ ស្ថានភាពពីសំណាក់ អង្គការ សហគមន៍ និងបុគ្គលនានាបានធ្វើឡើង ដើម្បីគ្រោងទុកជាមុន ធ្វើការឆ្លើយតប និងស្តារ ស្ថានភាពប្រកបដោយប្រសិទ្ធភាពខ្ពស់ ដើម្បីជើបចេញពីផលប៉ះពាល់នៃ*មុខសញ្ញាគ្រោះថ្នាក់* ឬលក្ខខណ្ឌដែលទំនងជា ជាក់លាក់ ឬ កំពុងកើតឡើង។

**Projection - ការធ្វើនិទស្សន៍**

ការវិវត្តនៃគុណភាព ឬ បរិមាណដែលអាចកើតឡើងទៅអនាគត ដែលជាញឹកញាប់ ត្រូវបានគណនា តាមរយៈម៉ូដែល។ និទស្សន៍ ត្រូវបានញែកដាច់ចេញពីការទស្សន៍ទាយ ដើម្បីគូសបញ្ជាក់ថា ចំណោលធ្វើឡើងដោយមានការសន្មតិ ដែលទាក់ទងជាមួយកត្តាមួយចំនួន ដូចជា ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម និងបច្ចេកវិទ្យាទៅអនាគត ដែលអាច ឬ មិនអាចកើតមានជាក់ស្តែង ដូច្នេះពាក់ព័ន្ធជាមួយភាពមិនប្រាកដប្រជាយ៉ាងច្រើន។ សូមអាន *និទស្សន៍អាកាសធាតុ* និង *ការទស្សន៍ទាយអាកាសធាតុ*។

## R.

**Radiative forcing - កម្លាំងកាំរស្មី**

កម្លាំងកាំរស្មី គឺជាការប្រែប្រួលនៃបន្សាយកាំរស្មីតាមទិសឈរ (គិតជា វ៉ាត់ ក្នុងមួយម៉ែត្រការ៉េ - $W/m^2$) នៅត្រង់ត្រូប៉ូផស (ព្រំប្រទល់រវាងត្រូប៉ូស្វ៊ែរ និងស្ត្រាតូស្វ៊ែរ) ដោយសារតែការប្រែប្រួលខាងក្នុង និងខាងក្រៅ នៃកម្លាំងថាមពលពន្លឺនៅក្នុង *ប្រព័ន្ធអាកាសធាតុ* ដូចជា ការប្រែប្រួលនៃកំហាប់ឧស្ម័នកាបូនិក ឬ កាំរស្មីពីព្រះអាទិត្យ។

**Relative sea level - កំពស់ទឹកសមុទ្រធៀប**

កំពស់ទឹកសមុទ្រវាស់ដោយ*រង្វាស់ទឹកជោរ-នាច* ដែលទាក់ទងនឹងដីដែលមានឧបករណ៍វាស់តាំងនៅ។ កម្ពស់ទឹកសមុទ្រជាមធ្យម តាមធម្មតាត្រូវបានកំណត់ដោយកម្រិតកំពស់ជាមធ្យមធៀបនៃទឹកសមុទ្រ នៅក្នុងអំឡុងពេលណាមួយ ដូចជា មួយខែ ឬ មួយឆ្នាំ ដែលមានរយៈពេលវែងគ្រប់គ្រាន់ សម្រាប់គណនាមធ្យមភាគនៃកំពស់មិនបិតបេរ ដូចជា រលក និងទឹកជោរ។

**Resilience - ភាពធន់ទ្រាំ**

សមត្ថភាពនៃប្រព័ន្ធសង្គម ឬ អេកូឡូស៊ី ក្នុងការទប់ទល់នឹងការរំខាន ទន្ទឹមនឹងរក្សាបាននូវរចនាសម្ព័ន្ធជាមូលដ្ឋាន និងវិធីដំណើរការរបស់ខ្លួន សមត្ថភាពសម្រាប់ចាត់ចែងខ្លួនឯងឡើងវិញ និងសមត្ថភាពដើម្បីបន្សាំទៅនឹងការប៉ះទង្គិច និងការប្រែប្រួល។

**Respiration - ដំណកដង្ហើម**

ដំណើរការដែលសារពាង្គកាយរស់ប្រើប្រាស់ ដើម្បីបម្លែងសារធាតុសរីរាង្គ ទៅជា*ឧស្ម័នកាបូនិក* ដោយបំភាយថាមពល និងប្រើប្រាស់អុកស៊ីហ្សែន។

**Response to climate change - ការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ**

សកម្មភាពមនុស្ស ដែលមានគោលដៅ*បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ* និង *កាត់បន្ថយការប្រែប្រួលអាកាសធាតុ*។

**Risk (climate-related) - ហានិភ័យ (ដែលទាក់ទងនឹងអាកាសធាតុ)**

លទ្ធផលពីអន្តរអំពើនៃ*មុខសញ្ញាគ្រោះថ្នាក់*រូបវន្ត ដែលមានសំណុំលក្ខណៈជាប្រព័ន្ធដែលរងឥទ្ធិពល ពោលគឺ *ភាពងាយខូចខាត* ឬ *ភាពងាយរងគ្រោះ* (សង្គម)។ ហានិភ័យក៏អាចចាត់ទុកថាជា បង្គុំនៃព្រឹត្តិការណ៍មួយ ភវនីយភាពរបស់វា និង

ផលវិបាកនានារបស់វាផងដែរ ពោលគឺ ហានិភ័យ ស្មើនឹងប្រូបាប៊ីលីតេនៃ*មុខសញ្ញាគ្រោះថ្នាក់*អាកាសធាតុ គុណនឹង*ភាពងាយរងគ្រោះ* នៃប្រព័ន្ធណាមួយ។

**Risk management - ការគ្រប់គ្រងហានិភ័យ**

ការអនុវត្តយុទ្ធសាស្ត្រនានា ដើម្បីបញ្ចៀសផលវិបាកនានាដែលមិនអាចទទួលយកបាន។ នៅក្នុងបរិបទនៃ*ការប្រែប្រួលអាកាសធាតុ ការបន្សាំ* និង*ការកាត់បន្ថយ* គឺជាជំពូកធំៗពីរនៃចំណាត់ការ ដែលត្រូវអនុវត្ត ដើម្បីបញ្ចៀសផលវិបាកដែលមិនអាចទទួលយកបាន។

## S.

**Salinisation - ការឡើងប្រៃ**

កំណើនកំហាប់អំបិលនៅក្នុងដី។

**Salt-water intrusion - ការជ្រាបចូលនៃទឹកប្រៃ**

ការដកថយនៃទឹកសាបនៅលើផ្ទៃដី ឬ ក្រោមដី ដោយសារការរុញច្រាននៃទឹកប្រៃ បណ្តាលមកពីទឹកប្រៃមានដង់ស៊ីតេ ធំជាង។ តាមធម្មតា បាតុភូតនេះកើតឡើងនៅក្នុងតំបន់ឆ្នេរ និងពាមសមុទ្រ ដោយសារតែការថយចុះឥទ្ធិពលនៃទឹកសាបនៅលើផ្ទៃដី (ដូចជា ការថយចុះនៃបរិមាណ*ទឹកហូរនៅលើផ្ទៃដី* និងវត្តមានទឹកក្រោមដី ឬ ដោយសារការទាញយកទឹកក្រោមដីមកប្រើប្រាស់ច្រើនហួសហេតុ) ឬ កំណើនឥទ្ធិពលនៃទឹកសមុទ្រ (ដូចជា *កំណើនកំពស់ទឹកសមុទ្រ*)។

**Scenario - សេណារីយ៉ូ**

សេចក្តីអធិប្បាយដែលអាចទុកចិត្តបាន និងជាញឹកញាប់ជាទម្រង់ងាយអំពីថាតើអនាគតនឹងវិវត្តន៍ទៅបែបណា ដោយផ្អែកលើការសន្មតិស៊ីសង្វាក់គ្នា និងមានសង្គតិភាពផ្ទៃក្នុង អំពីកត្តានាំមុខ និងទំនាក់ទំនងសំខាន់ៗ។ គេអាចទទួលបាន សេណារីយ៉ូពី*ការធ្វើទិទស្សន៍* ប៉ុន្តែច្រើនតែផ្អែកលើព័ត៌មានបន្ថែមមកពីប្រភពផ្សេងទៀត ជួនកាលជាការផ្សំគ្នាជាមួយ "*ខ្សែរឿង*បែបអត្ថាធិប្បាយ"។ សូមអាន*សេណារីយ៉ូអាកាសធាតុ សេណារីយ៉ូនៃការបំភាយ* និង *SRES*។

**Sea level rise - កំណើនកំពស់ទឹកសមុទ្រ**

កំពស់ទឹកសមុទ្រអាចប្រែប្រួល ទាំងនៅកម្រិតពិភពលោក និងនៅមូលដ្ឋាន ដោយសារតែ (១) ការប្រែប្រួលសណ្ឋាននៅបាតមហាសមុទ្រ (២) ការប្រែប្រួលនៃម៉ាសទឹកសរុប និង(៣) ការប្រែប្រួលនៃដង់ស៊ីតេទឹក។ កត្តានានាដែលនាំទៅរកកំណើនកំពស់ទឹកសមុទ្រនៅក្រោមលក្ខខណ្ឌនៃ*ការឡើងកំដៅផែនដី* រួមមាន កំណើននៃម៉ាសទឹកសរុប ដែលបានមកពីការរលាយទឹកកកសំឡីនិងទឹកកកនៅលើដែនដីគោក និងការប្រែប្រួលនៃដង់ស៊ីតេទឹក បណ្តាលមកពីកំណើនសីតុណ្ហភាពទឹកនៅក្នុងមហាសមុទ្រ និងការប្រែប្រួលនៃកម្រិតប្រៃ។ កំណើនធៀបនៃកំពស់ទឹកសមុទ្រ កើតមាននៅកន្លែងណាដែលមានកំណើនក្នុងមូលដ្ឋាននៃកំពស់ទឹកមហាសមុទ្រ ធៀបនឹងកំពស់ផ្ទៃដី ដែលអាចដោយសារតែកំណើនកំពស់ទឹកក្នុងមហាសមុទ្រ និង/ឬ ការស្រុតចុះនៃនីវ៉ូដី។

**Sea wall - ទំនប់រលក**

ជញ្ជាំង ឬ ទំនប់ដែលមនុស្សជាអ្នកសាងសង់នៅតាមបណ្តោយឆ្នេរសមុទ្រ ដើម្បីការពារជំនន់ទឹកសមុទ្រ។

**Sensitivity - ភាពងាយខូចខាត**

ភាពងាយខូចខាត គឺជាកម្រិតដែលប្រព័ន្ធមួយងាយរងគ្រោះ ឬមួយជាផលវិជ្ជមាន ឬ អវិជ្ជមាន ដោយសារតែ*វិសមរូបអាកាសធាតុ* ឬ *ការប្រែប្រួលអាកាសធាតុ*។ ឥទ្ធិពលអាចកើតឡើងដោយផ្ទាល់ (ដូចជា ការប្រែប្រួលនៃទិន្នផលដំណាំដែលជាការឆ្លើយតបទៅនឹងការប្រែប្រួលនៃសីតុណ្ហភាពមធ្យម ចម្ងាយ និងវិសមរូប) ឬ ដោយប្រយោល (ដូចជា ការខូចខាតដោយសារកំណើនភាពញឹកញាប់នៃទឹកជំនន់នៅក្នុងតំបន់ឆ្នេរ ដោយសារតែ*កំណើនកំពស់ទឹកសមុទ្រ*)។

**Sequestration - ការស្រូបយក**

សូមអាន*សម្រូបកាបូន*។

**Sink – អាងស្រូបកាបូន**

ដំណើរការ សកម្មភាព ឬ យន្តការ ដែលស្រូបយក*ឧស្ម័នផ្ទះកញ្ចក់ អាអេរ៉ូសូល* ឬ ជាតុផ្សំណាមួយនៃ*ឧស្ម័នផ្ទះកញ្ចក់* ឬ *អាអេរ៉ូសូល* ពីក្នុង*បរិយាកាស*។

**Snow water equivalent - សមមូលជាទឹកនៃទឹកកក**

សមមូលនៃមាឌ/ម៉ាសទឹក ដែលអាចបង្កើតឡើងបាន ប្រសិនបើទឹកកកសំឡី ឬ ទឹកកក នៅតំបន់ណាមួយរលាយ។

**Socio-economic scenario - សេណារីយ៉ូសង្គម-សេដ្ឋកិច្ច**

*សេណារីយ៉ូ* ដែលទាក់ទងនឹងលក្ខខណ្ឌទៅអនាគត នៃចំនួនប្រជាជន *ផលទុនក្នុងស្រុកសរុប* និងកត្តាសង្គម-សេដ្ឋកិច្ចផ្សេងទៀត ដែលទាក់ទងនឹងការយល់ដឹងអំពីការពាក់ព័ន្ធនៃ*ការប្រែប្រួលអាកាសធាតុ*។ សូមអាន *SRES*។

**Solar radiation - កាំរស្មីព្រះអាទិត្យ**

កាំរស្មីអេឡិចត្រូម៉ាញ៉េទិក ដែលភាយចេញពីព្រះអាទិត្យ។ គេក៏ហៅផងដែរថាជា កាំរស្មីរលកជំហានខ្លី។ កាំរស្មីព្រះអាទិត្យមានជំហានរលក(សំណាយ)ខុសប្លែកពីគេ ដោយសារសីតុណ្ហភាពខ្ពស់បំផុតនៃព្រះអាទិត្យ ដែលសំបូររលកជំហានខ្លីដែលអាចមើលឃើញ។

**SRES - សេណារីយ៉ូ SRES**

*ខ្សែរឿង* និងចំនួនប្រជាពលរដ្ឋដែលពាក់ព័ន្ធ ផលទុនក្នុងស្រុកសរុប និង*សេណារីយ៉ូនៃការបំភាយ* ដែលពាក់ព័ន្ធជាមួយរបាយការណ៍ពិសេសស្តីពីសេណារីយ៉ូបំភាយ (SRES) (យោងតាម Nakićenovićet al., 2000)និងលទ្ធផលអំពី*ការប្រែប្រួលអាកាសធាតុ* និង *សេណារីយ៉ូនៃកំណើនកំពស់ទឹកសមុទ្រ*។ មាន*សេណារីយ៉ូសង្គម-សេដ្ឋកិច្ច*ចំនួនបួន (A1, A2, B1 និង B2) តំណាងឲ្យអនាគតខុសៗគ្នាលើពិភពលោក នៅក្នុងវិមាត្រខុសគ្នាចំនួនពីរ ពោលគឺ ការផ្តោតលើសេដ្ឋកិច្ច ធៀបនឹងកង្វល់បរិស្ថាន និងសណ្ឋាននៃការអភិវឌ្ឍនៅកម្រិតពិភពលោក ធៀបនឹងការអភិវឌ្ឍន៍នៅថ្នាក់តំបន់។

**Stakeholder - អ្នកពាក់ព័ន្ធ**

បុគ្គលម្នាក់ ឬ ស្ថាប័នមួយ ដែលមានផលប្រយោជន៍ស្របច្បាប់ នៅក្នុងគម្រោង ឬ អង្គភាពណាមួយ ឬ នឹងអាចរងឥទ្ធិពលដោយសារតែចំណាត់ការ ឬ គោលនយោបាយណាមួយ។

**Stimuli** – កត្តាជម្រុញ/ គ្រឿងភ្ញោច

ធាតុទាំងអស់នៃ*ការប្រែប្រួលអាកាសធាតុ* ដែលរួមទាំង សំណុំលក្ខណៈអាកាសធាតុមធ្យម *វិសម្យបអាកាសធាតុ* និង ភាពញឹកញាប់ និងទំហំនៃព្រឹត្តិការណ៍កំណាច។

Storyline - **ខ្សែរឿង**

សេចក្តីអធិប្បាយបែបពិពណ៌នាអំពី*សេណារីយ៉ូមួយ* (ឬ *សេណារីយ៉ូ* មួយក្រុម) ដែលគូសបញ្ជាក់អំពីសំណុំលក្ខណៈចំបងៗនៃ*សេណារីយ៉ូ* ទំនាក់ទំនងរវាងកត្តានាំមុខសំខាន់ៗ និងឌីណាមិកនៃ*សេណារីយ៉ូ*។

Strategy - **យុទ្ធសាស្ត្រ**

ផែនការសកម្មភាពទូលាយមួយ ដែលត្រូវអនុវត្តតាមរយៈគោលនយោបាយ និងវិធានការ។ **យុទ្ធសាស្ត្របន្សាំនឹងការប្រែប្រួលអាកាសធាតុ** សម្រាប់ប្រទេសមួយ សំដៅលើ ផែនការសកម្មភាពទូទៅមួយ សម្រាប់ដោះស្រាយ*ផលប៉ះពាល់*នៃ *ការប្រែប្រួលអាកាសធាតុ* ដែលរួមទាំង *វិសម្យបអាកាសធាតុ* និងព្រឹត្តិការណ៍កំណាច។ វាអាចរាប់បញ្ចូលគោលនយោបាយ និងវិធានការចម្រុះ ដែលបានជ្រើសរើស ដើម្បីឆ្លើយតបទៅនឹងគោលបំណងធំទូលាយនៃការកាត់បន្ថយ ភាពងាយរងគ្រោះរបស់ប្រទេស។

Stratosphere - **ស្ត្រាតូស្វ៊ែរ**

តំបន់ដែលមានភាពខុសគ្នាជាខ្លាំងនៃ*បរិយាកាស*នៅស្រទាប់ខាងលើក្នុង*ត្រូប៉ូស្វ៊ែរ* ដែលលាតសន្ធឹងចាប់ពីចម្ងាយប្រមាណ ១០គ.ម (ចាប់ពី៩គ.ម ក្នុងតំបន់ដែលមានរយៈទទឹងខ្ពស់ ដល់ ១៦គ.ម នៅក្នុងតំបន់ត្រូពិក) រហូតដល់ប្រមាណ ៥០គ.ម។

## T.

Thermal expansion - **ការរីកមាឌដោយសារកំដៅ**

ទាក់ទងនឹង*កំណើនកំពស់ទឹកសមុទ្រ* ពាក្យនេះសំដៅលើកំណើនបរិមាណ (និងការថយចុះនៃដង់ស៊ីតេ) ដែលកើតឡើងដោយសារទឹកដែលកាន់តែក្តៅ។ ទឹកសមុទ្រដែលកាន់តែក្តៅ នាំឲ្យមានការរីកមាឌ ដែលនាំឲ្យមានកំណើនកំពស់ទឹក។

Thermal infrared radiation - **កាំរស្មីអាំងប្រាកំដៅ**

កាំរស្មីភាយចេញពីផ្ទៃផែនដី *បរិយាកាស* និង ពពក។ គេហៅផងដែរថាជា *កាំរស្មីផែនដីគោក* ឬ *កាំរស្មីលេកជំហានវែង* និងត្រូវបានញែកដាច់ចេញពីកាំរស្មីក្បែរអាំងប្រា ដែលជាផ្នែកមួយនៃបាច់ពន្លឺពីព្រះអាទិត្យ។ ជាទូទៅ *កាំរស្មីអាំងប្រា* មានរប៉ាយដោយឡែកនៃជំហានរលក (*បាច់ពន្លឺ*) ដែលវែងជាងជំហានរលកពណ៌ក្រហមដែលស្ថិតនៅក្នុងផ្នែកដែលអាចមើលឃើញនៃបាច់ពន្លឺ។ បាច់ពន្លឺនៃកាំរស្មីអាំងប្រាកំដៅ មានភាពខុសគ្នាពីបាច់ពន្លឺដែលមានជំហានរលកខ្លី ឬ *កាំរស្មីព្រះអាទិត្យ* ដោយសារតែភាពខុសគ្នានៃសីតុណ្ហភាព រវាងព្រះអាទិត្យ និងប្រព័ន្ធផែនដី-*បរិយាកាស*។

Threshold - **ចំណុចចាប់ផ្តើម**

កម្រិតវិសាលភាពនៃដំណើរការរបស់ប្រព័ន្ធណាមួយ ដែលក្នុងនោះមានការប្រែប្រួលភ្លាមៗ ឬយ៉ាងឆាប់រហ័ស។ ចំណុច ឬ កម្រិតមួយដែលកើតមានសំណុំលក្ខណៈថ្មីៗនៃអេកូឡូស៊ី សេដ្ឋកិច្ច ឬ ប្រព័ន្ធដទៃទៀត ដែលបង្ហាញឲ្យឃើញពីភាពខុសគ្នាធៀបនឹងការប៉ាន់ស្មានដែលផ្អែកលើទំនាក់ទំនងគណិតសាស្ត្រ ដែលមានការពាក់ព័ន្ធនៅកម្រិតទាបជាង។

**Tide gauge - រង្វាស់ទឹកជោរ-នាច**

ឧបករណ៍មួយនៅក្នុងតំបន់ឆ្នេរ( និងនៅតាមទីតាំងជ្រៅៗខ្លះនៃសមុទ្រ) ដែលវាស់ជាប់ជាប្រចាំនូវកម្រិតកំពស់ទឹកសមុទ្រ ធៀបនឹងដីដែលនៅក្បែរខាង។ កម្រិតកំពស់ទឹកគិតជាមធ្យមនៅក្នុងចន្លោះពេលដែលវាស់បែបនេះ បង្ហាញពីការប្រែប្រួល ដែលបានសង្កេតឃើញជាក់ស្តែងនៃកម្រិតកំពស់ធៀបនៃទឹកសមុទ្រ។ សូមអាន *ការប្រែប្រួលកំពស់ទឹកសមុទ្រ/កំណើន កំពស់ទឹកសមុទ្រ*។

**Troposphere - ត្រូប៉ូស្វែរ(មណ្ឌលអាកាសរចល់)**

ផ្នែកនៅទាបជាងគេនៃ*បរិយាកាស* គិតចាប់ពីផ្ទៃដី រហូតដល់ចម្ងាយប្រមាណ ១០គ.ម គិតជារយៈកំពស់ នៅក្នុងតំបន់ ដែលមានរយៈទទឹងមធ្យម (ប្រែប្រួលពី ៩គ.ម នៅកន្លែងមានរយៈទទឹងខ្ពស់ ដល់១៦គ.មជាមធ្យម នៅក្នុងតំបន់ត្រូពិក) ដែលកើតមានបាតុភូតពពក និង*ធាតុអាកាស*។ នៅក្នុងត្រូប៉ូស្វែរ ជាទូទៅ សីតុណ្ហភាពថយចុះ កាលណាគេឡើងកាន់តែ ខ្ពស់។

## U.

**Uncertainty - ភាពមិនប្រាកដប្រជា**

ពាក្យមួយ ដែលបង្ហាញអំពីទំហំ (ដូចជា ស្ថានភាពទៅអនាគតនៃ*ប្រព័ន្ធអាកាសធាតុ*) ដែលតំលៃមួយមិនត្រូវបានដឹង ប្រាកដ។ ភាពមិនប្រាកដប្រជា អាចកើតចេញពីកង្វះព័ត៌មាន ឬ ការមិនឯកភាពគ្នាអំពីអ្វីដែលដឹង ឬ ដែលអាចដឹងបាន ផងដែរ។ វាអាចមានប្រភពខុសៗគ្នា ដែលរាប់ចាប់ពីកំហុសដែលអាចគណនាបាននៃទិន្នន័យ រហូតដល់គោលគំនិត ឬ បច្ចេកស័ព្ទដែលមានការកំណត់និយមន័យមិនច្បាស់លាស់ ឬ *ទិទស្សន៍*មិនច្បាស់លាស់ អំពីឥរិយាបថរបស់មនុស្ស។ ដូច្នេះ ភាពមិនប្រាកដប្រជា អាចតំណាងដោយរង្វាស់បរិមាណ (ដូចជា តួលេខនានាដែលគណនាតាមរយៈម៉ូដែលខុសៗ គ្នា) ឬ អំណះអំណាងជាគុណភាព (ដូចជា ដែលឆ្លុះបញ្ចាំងអំពីការវិនិច្ឆ័យរបស់អ្នកជំនាញការមួយក្រុម)។

**United Nations Framework Convention on Climate Change (UNFCCC) - អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិ ស្តីពី ការប្រែប្រួលអាកាសធាតុ**

អនុសញ្ញាស្តីពីអាកាសធាតុចែងអំពីក្របខ័ណ្ឌរួមមួយសម្រាប់កិច្ចប្រឹងប្រែងអន្តររដ្ឋាភិបាល ដើម្បីដោះស្រាយការប្រឈម បង្កដោយ*ការប្រែប្រួលអាកាសធាតុ*។ អនុសញ្ញានេះទទួលស្គាល់ថា *ប្រព័ន្ធអាកាសធាតុ* គឺជាធនធានរួម ដែលស្ថិរភាព របស់វា អាចស្ថិតក្រោមឥទ្ធិពលនៃការបំភាយឧស្ម័នកាបូនិក និងឧស្ម័នផ្សេងទៀតពីឧស្សាហកម្ម និងពីប្រភពផ្សេងទៀត។

## V.

**Vulnerability - ភាពងាយរងគ្រោះ**

ភាពងាយរងគ្រោះគឺជាកម្រិតដែលប្រព័ន្ធមួយងាយទទួលឥទ្ធិពល និងមិនអាចទប់ទល់នឹងឥទ្ធិពលអវិជ្ជមាននៃ*ការប្រែ ប្រួលអាកាសធាតុ* ដែលរួមទាំង *វិសមរូបអាកាសធាតុ* និងបាតុភូតកំណាចផងដែរ។ ភាពងាយរងគ្រោះគឺជាអនុគមន៍នៃ

ប្រភេទ ទំហំ និងអត្រានៃ*ការប្រែប្រួលអាកាសធាតុ* និងភាពខុសៗគ្នានៃឥទ្ធិពលដែលមានមកលើប្រព័ន្ធមួយ *ភាពងាយខូចខាត* និងសមត្ថភាពបន្សាំរបស់ប្រព័ន្ធនោះ។

**Vulnerability assessment - ការប៉ាន់ប្រមាណភាពងាយរងគ្រោះ**

ការប៉ាន់ប្រមាណភាពងាយរងគ្រោះ កំណត់អំពីអ្នកណា ឬ អ្វី ដែលរងឥទ្ធិពល ឬ ងាយខូចខាត ដោយសារតែការប្រែប្រួលនៃមជ្ឈដ្ឋានខាងក្រៅ។ ការប៉ាន់ប្រមាណភាពងាយរងគ្រោះ ចាប់ផ្តើមដោយពិចារណាកត្តានានា ដែលធ្វើឲ្យមនុស្ស ឬ បរិស្ថានងាយរងការខូចខាត ពោលគឺ សិទ្ធិក្នុងការទទួលបានធនធានធម្មជាតិ និងហិរញ្ញវត្ថុ សមត្ថភាពដើម្បីការពារខ្លួន បណ្តាញគាំទ្រ ។ល។

## W.

**Weather - ធាតុអាកាស**

លក្ខខណ្ឌបរិយាកាសនៅក្នុងពេល ឬទីកន្លែងណាមួយ។

ធាតុអាកាសត្រូវបានវាស់ក្រោមរូបភាពជា កម្លាំងខ្យល់ សីតុណ្ហភាព សំណើម សម្ពាធបរិយាកាស កម្រិតពពក និងកំពស់ទឹកភ្លៀង។ នៅក្នុងកន្លែងភាគច្រើន ធាតុអាកាសអាច ប្រែប្រួលរៀងរាល់ម៉ោង ថ្ងៃ និង រដូវ។ ក្នុងន័យចង្អៀត តាមធម្មតា *អាកាសធាតុ* ត្រូវបានឲ្យនិយមន័យថាជា "តួលេខ មធ្យមនៃធាតុអាកាស" ឬ ហ្មត់ចត់ជាងនេះ គឺជា ការពិពណ៌នាជាតួលេខស្ថិតិគិតជាមធ្យម និងវិសមរូបនៃបរិមាណដែល ពាក់ព័ន្ធនៅក្នុងអំឡុងពេលណាមួយ ដែលរាប់ចាប់ពីជាច្រើនខែ ដល់រាប់ពាន់ ឬ លានឆ្នាំ។ តាមធម្មតា រយៈពេល ៣០ឆ្នាំ ត្រូវបានកំណត់ដោយអង្គការឧតុនិយមពិភពលោក (WMO)។ ជាញឹកញាប់បំផុត បរិមាណទាំងនេះគឺជាអថេរនៃលក្ខខណ្ឌនៅលើផ្ទៃផែនដី ដូចជា សីតុណ្ហភាព កំពស់ទឹកភ្លៀង និងខ្យល់។ ក្នុងន័យទូលាយជាងនេះ *អាកាសធាតុ* គឺជា ស្ថានភាព ដែលរួមទាំង ការពិពណ៌នាជាស្ថិតិ អំពី*ប្រព័ន្ធអាកាសធាតុ*។ វិធីងាយមួយនៃការចងចាំភាពខុសគ្នាគឺថា *អាកាសធាតុ* គឺជាអ្វីដែលអ្នករំពឹងទុក (ដូចជា រដូវធ្លាក់ទឹកកកដែលត្រជាក់ជាងធម្មតា) និង "ធាតុអាកាស" ជាអ្វីដែល អ្នកបានជួបប្រទះ (ដូចជា ព្យុះទឹកកក)។

**Weather prediction/forecast - ការទស្សន៍ទាយ/ព្យាករណ៍ធាតុអាកាស**

ការប្រើប្រាស់វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដើម្បីទស្សន៍ទាយអំពីស្ថានភាពនៃ*បរិយាកាស* សម្រាប់អំឡុងពេលទៅអនាគត និងសម្រាប់ទីកន្លែងណាមួយ។

មនុស្សបានប៉ុនប៉ងធ្វើការទស្សន៍ទាយ*ធាតុអាកាស* តាមរូបភាពមិនផ្លូវការអស់រយៈពេលជាច្រើនសហស្សវត្សរ៍មកហើយ និងជាផ្លូវការ ចាប់តាំងពីយ៉ាងហោចណាស់នៅក្នុងសតវត្សរ៍ទី១៩។ ការព្យាករណ៍ធាតុអាកាស បានធ្វើឡើង ដោយការប្រមូលទិន្នន័យជាបរិមាណ អំពីស្ថានភាពបច្ចុប្បន្ននៃ*បរិយាកាស* និងប្រើប្រាស់ការយល់ដឹងតាមបែបវិទ្យាសាស្ត្រអំពីដំណើរការនៅក្នុងបរិយាកាស ដើម្បីនិទស្សន៍ថាតើ*បរិយាកាស* វិវត្តបែបណា។

## ឯកសារយោង


APDC. (2010). Regional training manual on disaster risk reduction for coastal zone managers. Retrieved 12 May 2011, from http://www.mangrovesforthefuture.org/Assets/documents/DRR_coastal%20zone%20managers_reg_manual.pdf

CARE International. (2008). *Care International in Vietnam climate change strategy 2008-2013*. Hanoi, Viet Nam.

FAO. (2004). Global forest resources assessment update 2005: Terms and definitions. Retrieved 16 December 2010, from ftp://ftp.fao.org/docrep/fao/007/ae156e/AE156E00.pdf

IPCC. (2007). IPCC fourth assessment report: Working Group I: The physical science basis: Glossary. Retrieved12 May 2011, from http://www.ipcc.ch/pdf/glossary/ar4-wg1.pdf

IPCC. (2007). IPCC fourth assessment report: Working Group II: Impacts, adaptation and vulnerability: Glossary. Retrieved 13 May 2011, from http://www.ipcc.ch/pdf/glossary/ar4-wg2.pdf

IPCC. (2007). IPCC fourth assessment report: Working Group III: Mitigation of climate change: Glossary. Retrieved 13 May 2011, from http://www.ipcc.ch/pdf/glossary/ar4-wg3.pdf

IPCC. (2007). IPCC fourth assessment report: The AR4 synthesis report: Glossary. Retrieved 13 May 2011, from http://www.ipcc.ch/pdf/assessment-report/ar4/syr/ar4_syr_appendix.pdf

IPCC. (2001). *Climate change 2001: Impacts, adaptation and vulnerability*: Contribution of Working Group II to the third assessment report of the Intergovernmental Panel on Climate Change. Cambridge: Cambridge University Press.

IPCC. (2001). *Climate change 2001: The scientific basis*: Contribution of Working Group I to the third assessment report of the Intergovernmental Panel on Climate Change. Cambridge: Cambridge University Press.

Levina, E., & Tirpak, D. (2006). Key adaptation concepts and terms. Retrieved 22 June 2010, from http://www.oecd.org/dataoecd/42/30/36278739.pdf

Burton, I., Malone, E., & Huq, S. (2005). *Adaptation policy frameworks for climate change: Developing strategies, policies and measures*. New York: Cambridge University Press.

NOAA. (n.d.). Climate glossary. Retrieved 16 December 2010 from, http://www.ncdc.noaa.gov/paleo/ctl/glossary.html

Pittock, B (Ed.). (2003). *Climate change: An Australian guide to the science and potential impacts*. Canberra, Commonwealth of Australia: Australian Greenhouse Office.

Presidency of Meteorology and Environment. (2010). *Millennium ecosystem assessment: Sub-global Arab millennium ecosystem assessment* (Summary of chapters). Retrieved 13 May 2011, from http://www.pme.gov.sa/en/Summary1.pdf

PwC. (2009). *Climate change: Glossary of terms*. Retrieved 16 December 2010, from http://www.pwc.com/en_LU/lu/corporate-responsibility/docs/pwc_csrglossaryofterms.pdf

Tompkins, E. L., et al. (2005). *Surviving climate change in small islands*: *A guidebook*. UK: Tyndall Centre for Climate Change Research.

UNFCCC. (2007). GHG inventories: Glossary. Retrieved 22 June 2011, from http://unfccc.int/resource/cd_roms/na1/ghg_inventories/english/8_glossary/Glossary.htm

UNISDR. (2004). *Living with risk: A global review of disaster reduction initiatives*. New York: United Nations.

US EPA. (n.d.). Glossary of climate change terms. Retrieved 16 December 2010, from http://www.epa.gov/climatechange/glossary.html

van Everdingen, R (Ed.). (1998). Multi-language glossary of permafrost and related ground-ice terms. Boulder, CO: National Snow and Ice Data Center/World Data Center for Glaciology (revised May 2005). Retrieved 16 December 2010, from http://nsidc.org/fgdc/glossary/